ឆ្នាំគ្រួសារ ២០១៧-២០២០

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៨ លក់តម្លៃ ១០០០រៀល

លេខ ១០៨




# ពលរដ្ឋយល់ខុសៗគ្នាអំពីកំណើនវត្តមានជនជាតិចិនមកខេត្តព្រះសីហនុ

Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org

https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្ដីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

CARITAS CHRISTI URGET NOS

**លេខ: ០១៦/ ២០១៨-អភ**

**ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨**
**ថ្ងៃពុធ ជាបុណ្យរោយផេះ**

បងប្អូនជាស្រឡាញ់!

**"ចូរនាំគ្នាទទួលដំណឹងល្អដោយចិត្តស្មោះ និងចូរប្រែចិត្តគំនិត"**

ព្រះសហគមន៍អញ្ជើញយើងក្នុងរដូវត្រណម ឲ្យគិតគូរអំពីសេចក្តីសំខាន់ក្នុងការរស់នៅជាគ្រីស្តបរិស័ទ គឺយើងទទួលដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្ត ដោយសុខចិត្តប្រែចិត្តគំនិត ដើម្បីរួមរស់ជាមួយព្រះយេស៊ូយ៉ាងស្និទ្ធស្នាលដែលស្រឡាញ់ព្រះបិតា។

ឆ្នាំនេះ នៅក្នុងឱកាសបុណ្យចម្លង យើងមាន៧០នាក់ទទួលអគ្គសញ្ញាជ្រមុជទឹក។ ខ្ញុំនឹងត្រាស់ហៅបងប្អូនជាផ្លូវការ នៅថ្ងៃទី១៥ កុម្ភៈ នៅព្រះសហគមន៍ជ្រៃធំ (បាសាក់១៥នាក់) និងនៅថ្ងៃទី១៨កុម្ភៈនៅព្រះសហគមន៍ភ្នំពេញថ្មី (៥៥នាក់)។ ខ្ញុំសូមផ្ញើបងប្អូនទាំងនោះក្នុងព្រះហស្តព្រះជាម្ចាស់ សូមបងប្អូនអង្វរព្រះជាម្ចាស់ឲ្យគេផង។

ក្នុងរដូវត្រណមខាងមុខនេះ សម្តេចប៉ាបបានអញ្ជើញយើងឲ្យអង្វរព្រះបិតា ឲ្យតមអាហារ និងឲ្យបំពេញកិច្ចការប្រកបដោយមនុស្សធម៌ ក្នុងគោលបំណងដកសេចក្តីអាក្រក់ដែលមានចាក់ឫសក្នុងខ្លួនយើង។ សេចក្តីអាក្រក់ទាំងនេះ រាំងយើងមិនឲ្យរស់នៅតាមសេចក្តីស្រឡាញ់របស់ព្រះបិតាយ៉ាងពេញលេញ និងរាំងយើងមិនឲ្យចែកសេចក្តីស្រឡាញ់នោះចំពោះបងប្អូនដែលខ្វះខាត។ ខ្ញុំសូមផ្ញើលិខិតរបស់សម្តេចប៉ាបភ្ជាប់និងសំបុត្រនេះ។ ខ្ញុំសូមអញ្ជើញបងប្អូនអានលិខិតនោះ និងរិះគិតដោយសួរគ្នីគ្នាថា

**"តើមានអ្វីរាំងខ្ញុំឲ្យទៅជាសញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់របស់ព្រះបិតាចំពោះបងប្អូន?"**

ម៉្យាងទៀត ខ្ញុំសូមអញ្ជើញឲ្យបងប្អូនចាត់ចែងពីធីអធិដ្ឋាន២៤ម៉ោង ក្នុងគ្រប់តំបន់ នៅថ្ងៃសៅរ៍ទី១០ ខែមេសា (ម៉ោង០៦ព្រឹក) រហូតដល់ថ្ងៃអាទិត្យទី១១ ខែមេសា ឆ្នាំ២០១៨ (ម៉ោង១២ថ្ងៃត្រង់)។ ពេលវេលានៃការថ្វាយបង្គំព្រះកាយព្រះគ្រីស្ត និងទទួលអគ្គសញ្ញាលើកលែងទោស នឹងជួយឲ្យបងប្អូនប្រែចិត្តគំនិត ដើម្បីទទួលព្រះអម្ចាស់ដែលមានព្រះជន្មថ្មីដ៏រុងរឿងក្នុងឱកាសបុណ្យចម្លង។

ឆ្នាំនេះ ជាឆ្នាំនៃក្រុមគ្រួសារ គឺយើងនឹកគិតដល់ក្រុមគ្រួសារទាំងអស់។ ក្នុងរដូវត្រណមនេះ ខ្ញុំសូមអញ្ជើញបងប្អូនចែកពេលវេលាដើម្បីអង្វរព្រះបិតាក្នុងរង្វង់សារនិងសូមស្នឹងស្មាធិ៍ព្រះបន្ទូលរបស់ព្រះអង្គ។ រៀងរាល់ថ្ងៃអាទិត្យ មុនថ្វាយអភិបូជា គេនឹងចែកអត្ថបទគម្ពីរដំណឹងល្អប្រចាំថ្ងៃអាទិត្យនេះឲ្យបងប្អូនយកទៅផ្ទះ ដើម្បីអានជាមួយគ្នារួមជាមួយបងប្អូនក្នុងអាទិត្យខាងមុខ ដោយសួរគ្នីគ្នាថា

**"តើព្រះបន្ទូលរបស់ព្រះជាម្ចាស់នេះ ពិតជាពន្លឺបំភ្លឺការរស់នៅរបស់ខ្ញុំជារៀងរាល់ថ្ងៃ?"**

ជាទីបញ្ចប់ ខ្ញុំសូមឲ្យបងប្អូនអង្វរព្រះបិតាសម្រាប់អស់លោកអ្នកដែលនឹងបំពេញមុខងារផ្សេងតាមព្រះសហគមន៍នីមួយៗ និងក្នុងភូមិភាគយើងទាំងមូល៕

APOSTOLIC VICARIATE PHNOM PENH

អូលីវីយេ ឆ្មឺតហាស្លេរ
អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

# អ្នកជំនាញជំនឿថា សត្វព្រៃជាប្រភពឱសថ "ជាការយល់ខុស"



ថតដោយ: WCS

ដោយសារតែម្នាក់ៗមានជំនឿថាសត្វព្រៃជាគ្រឿងផ្សំឱសថ បានជំរុញឲ្យមានការប្រមាញ់សត្វព្រៃដែលកំពុងរងការគំរាមកំហែងធ្ងន់ធ្ងរ និងឈានទៅរកការវិនាសផុតពូជ ប៉ុន្តែក្រុមអ្នកអភិរក្សនិយាយថា ជំនឿរបស់ប្រជាពលរដ្ឋនេះមិនសមស្របនោះទេ ហើយមន្ត្រីក៏បានព្រមានថា អ្នកបរបាញ់និងអ្នកជួញដូរប្រភេទសត្វព្រៃកម្រនឹងត្រូវផ្តន្ទាទោសរហូតអាចជាប់ពន្ធនាគារ។

ក្រុមអ្នកអភិរក្សបរិស្ថាននបានអះអាងថា ជំនឿដែលថាសត្វព្រៃគឺជាប្រភពឱសថបុរាណដ៏ស័ក្តិសិទ្ធនោះ គឺជាការយល់ខុស "ទាំងស្រុង" និងជាជំនឿដែលនាំឲ្យមានការបំផ្លិចបំផ្លាញធនធានសត្វព្រៃឲ្យវិនាសផុតពូជ។

លោក ឈិត សំអាត ប្រធានអង្គការមូលនិធិសកល សម្រាប់ការពារធនធានធម្មជាតិ WWF បានផ្តល់បទសម្ភាសន៍កាលពីពេលកន្លងទៅនេះថា សត្វព្រៃនៅកម្ពុជា កំពុងតែរងនូវការវិនាសបាត់បង់ ព្រោះតែពលរដ្ឋយល់ខុសចំពោះការយកសត្វទាំងនោះ ថាជាថ្នាំព្យាបាលរោគច្រើនប្រភេទនោះ។

"នេះជាជំនឿតៗគ្នាមក។ តាមពិតទៅវាជាជំនឿទេ វាអត់ទាន់មានវេជ្ជសាស្ត្របញ្ជាក់ថា អាហ្នឹងវាធ្វើថ្នាំអីទេ ឧទាហរណ៍ដូចជាពង្រូលអី ដែលយកទៅធ្វើថ្នាំអីចឹង ហើយមនុស្សចេះតែជឿតៗគ្នា។ ប៉ុន្តែ ទាក់ទងនឹងពង្រូលតាមខ្ញុំដឹង វៀតណាមបានសិក្សាស្រាវជ្រាវទៅឃើញថា វាមិនមែនជាថ្នាំអីទេ នេះគ្រាន់តែជាជំនឿអរូបិយជឿតៗ គ្នាប៉ុណ្ណោះ" នេះបើតាមការអះអាងរបស់លោក ឈិត សំអាត។

លោកឈិត សំអាត បានបញ្ជាក់ថា ប្រទេសវៀតណាមបានពិសោធន៍លើប្រសិទ្ធិភាពនៃសត្វពង្រូល ហើយបានរកឃើញថា សត្វនេះគ្មានប្រយោជន៍ផ្នែកឱសថ ដូចដែលពលរដ្ឋខ្មែរនិយាយតៗគ្នានោះទេ។ ផ្ទុយទៅវិញសត្វព្រៃតែងតែមានជំងឺជាប់ខ្លួន ហើយវាអាចជាហានិភ័យសម្រាប់សុខភាពមនុស្ស។

លោកបានបញ្ជាក់ថា "សត្វព្រៃវាមានជំងឺ ព្រោះវាមិនបានចាក់ថ្នាំដូចសត្វក្នុងស្រុកទេ អីចឹងកាលណាយើងញ៉ាំទៅវានឹងបង្កឲ្យប៉ះពាល់ដល់សុខភាព។ យើងកុំជឿ ហើយករណីថ្នាំក៏មិនទាន់មានវេជ្ជសាស្ត្របញ្ជាក់ឲ្យច្បាស់លាស់ដែរ ដូច្នេះកុំទៅជឿពេក"។

ជាមួយគ្នានេះលោក ឈិត សំអាត បានអំពាវនាវដល់ពលរដ្ឋកម្ពុជាឲ្យចូលរួមអភិរក្សសត្វព្រៃនិងឈប់ប្រើប្រាស់ឈើប្រណិតដើម្បីស្ថិរភាពសត្វព្រៃទៅអនាគត និងដើម្បីចូលរួមចំណែកក្នុងការការពារប្រព័ន្ធបរិស្ថានធម្មជាតិសម្រាប់ជាជម្រកដល់សត្វព្រៃ។

ជាយូរយារណាស់មកហើយ ពលរដ្ឋកម្ពុជាក៏ដូចជាពលរដ្ឋនៅក្នុងតំបន់អាស៊ីជាច្រើនទៀតតែងតែជឿថា ក្រពះសត្វព្រៃ ឆ្អឹង ស្នែង ឬផ្នែកផ្សេងទៀតនៃសត្វព្រៃជាឱសថដ៏ពូកែ។ នៅក្នុងទីផ្សារងងឹតក្នុងប្រទេសកម្ពុជាសត្វកម្រមួយចំនួនកំពុងចរាចរជាលក្ខណៈបណ្តាញ។ សត្វទាំងនោះមានដូចជាពង្រូល អាញ៉ី តេស្ត គោព្រៃ ខ្ទីង និងសត្វអណ្តើកជាដើម។ សត្វភាគច្រើនត្រូវគេសម្លាប់រួចជាស្រេចទើបយកមកលក់ ប៉ុន្តែសត្វមួយចំនួនតូចត្រូវគេដាក់លក់ទាំងរស់ដោយលួចលាក់ និងដោយរក្សាការសម្ងាត់បំផុត។ ស្ត្រីជាឈ្មួញម្នាក់បានប្រកបមុខរបរនេះជាច្រើនឆ្នាំមកហើយ។ អ្នកស្រីក៏ជាអ្នកដែលអះអាងថាមានជំងឺ និងទទួលបានការព្យាបាលតាមរយៈការបរិភោគសត្វពង្រូល។ អ្នកស្រីបានអះអាងពីប្រសិទ្ធភាពនៃសត្វព្រៃជាឱសថមួយចំនួន។

លោក អេង ម៉េងអ៊ី មន្ត្រីទំនាក់ទំនងនៃអង្គការសមាគមអភិរក្សសត្វព្រៃ WCS មានប្រសាសន៍ថា ការលើកឡើងរបស់ឈ្មួញសត្វព្រៃខាងលើគ្រាន់តែជាជំនឿតគ្នារបស់ប្រជាពលរដ្ឋខ្មែរតែប៉ុណ្ណោះ។ លោក ម៉េងអ៊ី បានបកស្រាយស្របគ្នាទៅនឹងការបកស្រាយរបស់លោក ឈិត សំអាតដែរ។

លោកបានបញ្ជាក់ថា "កន្លងមកដូចយើងបានឮហើយ ដូចជាប្រភេទសត្វតេស្តដែលអ្នកខ្លះគេថា ហូបឈាមវាទៅព្យាបាលជំងឺនេះ យកឆ្អឹងវាមកត្រាំស្រាទៅព្យាបាលជំងឺនោះ តាមពិតទៅវាគឺជាជំនឿខុស ដោយសារគាត់យល់ថា សត្វតេស្តវារស់តាមតំបន់លើភ្នំ ហើយពេលណាវាមានជំងឺអីគេនិយាយតគ្នាថា កាលណាវាលិឍជើងវាទៅ វាព្យាបាលជាអីចឹង តាមពិតវាជាជំនឿខុស ហើយជំរុញឲ្យគាត់ហូបអីចឹងៗ"។

ព្រោះតែជំនឿខុសនេះ បានធ្វើឲ្យពលរដ្ឋមួយចំនួននៅតែឆ្លៀតលួចបរបាញ់សត្វព្រៃដោយខុសច្បាប់។ សត្វព្រៃជាច្រើនប្រភេទដែលកំពុងទទួលរងការគំរាមកំហែងពីការលួចបរបាញ់រួមមាន សត្វឈ្លូស ប្រើសរមាំង ទន្សោង និងខ្ទីង សម្រាប់យកសាច់និងស្នែង។

លោក អេង ម៉េងអ៊ី បានសង្កត់ធ្ងន់ថា "តាមអ្វីយើងស្រាវជ្រាវ ក៏ដូចជាអ្វីដែលយើងសិក្សាកន្លងមកវាជាជំនឿខុសព្រោះថា សត្វមួយចំនួនវាផ្ទុកទៅដោយជំងឺ ហើយកាលណាគាត់យកទៅហូបហ្នឹងវាមិនបង្កើនសុខភាព វាបែរជាបង្កើនជំងឺទៅវិញ ហើយការយល់ខុស វាមិនថែមទាំងធ្វើឲ្យប៉ះពាល់សុខភាពគាត់ ហើយធ្វើឲ្យបាត់បង់សត្វព្រៃថែមទៀត"។

លោក អេង ម៉េងអ៊ី យល់ថា ការកាប់បំផ្លាញព្រៃឈើ ក៏ជាផ្នែកមួយដែលជួយពន្លឿន ការសម្លាប់សត្វព្រៃពីអ្នកលួចបរបាញ់ដែរព្រោះបើគ្មានកន្លែងលាក់ខ្លួនសត្វព្រៃងាយនឹងត្រូវគេរកឃើញណាស់ដោយសារពួកវាត្រូវការបម្លាស់ទី។ មន្ត្រីនៃអង្គការសមាគមអភិរក្សសត្វព្រៃ WCS និយាយថា ដើម្បីរក្សាសត្វព្រៃឲ្យនៅគង់វង្សបានលុះត្រាតែមានការចូលរួមពីពលរដ្ឋដោយឈប់បរិភោគសាច់ និងបញ្ឈប់ការទិញឬជួញសត្វព្រៃ។

កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ បុរសចំការពីរនាក់ដែលរស់នៅក្នុងស្រុកកែវសីមា ត្រូវបានចាប់បញ្ជូនទៅកាន់សាលាដំបូង ខេត្តមណ្ឌលគិរី ក្រោមបទសង្ស័យថា បានសម្លាប់សត្វស្វាកន្ទុយសចំនួនពីរក្បាល ក្នុងតំបន់អភិរក្សសត្វព្រៃជម្រកដែនសីមា ដើម្បីយកក្រពះធ្វើជាឱសថបុរាណ។

ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ មាត្រា ៤៩ បានចែងថា ហាមឃាត់ដាច់ខាតរាល់សកម្មភាពបរបាញ់ យាយីបំផ្លាញសត្វព្រៃគ្រប់ប្រភេទ ជាពិសេសការដឹកជញ្ជូន ការធ្វើពាណិជ្ជកម្ម និងការនាំចេញនាំចូល។ យោងលើច្បាប់តំបន់ការពារនៃព្រះរាជាណាចក្រកម្ពុជា ការ បរបាញ់សត្វព្រៃ ប្រភេទរងគ្រោះជិតផុតពូជ អាចប្រឈមនឹងការជាប់ពន្ធនាគារ ចាប់ពី ១ - ៥ឆ្នាំ និងអាចរងការពិន័យអន្តរការ ជាទឹកប្រាក់ពី ១៥ទៅ ១០០លានរៀល ឬស្មើនឹង ៣.៧៥០ដុល្លារ ដល់ ២៥.០០០ ដុល្លារអាមេរិក។

ប្រទេសកម្ពុជាមានតំបន់ព្រៃអភិរក្សចំនួន៤៦ និងតំបន់អភិរក្សជីវចម្រុះមួយដែលគ្របដណ្តប់លើតំបន់មាននៅខាងកើតទន្លេមេគង្គ ខាងជើងទន្លេសាប និងតំបន់ខាងត្បូងទន្លេសាប។ តំបន់ការពារទាំងនេះមានផ្ទៃដីសរុបចំនួន៧,៥លានហិចតា៕

*ដោយ សុផានិត*

# ឆ្នាំ២០១៨ចំណូលពលរដ្ឋកម្ពុជាម្នាក់ៗនឹងឡើងដល់១.៥៦៨ដុល្លារ



រូបថត លីហៀង

មន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជាមួយរូបបានបង្ហាញនូវសុទិដ្ឋិនិយមថា នៅក្នុងឆ្នាំ២០១៨នេះ ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋកម្ពុជាម្នាក់ៗនឹងអាចឡើងដល់កម្រិត១.៥៦៨ដុល្លារនៅក្នុងមួយឆ្នាំ។

លោកវង្សីវិស្សុតរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានមានប្រសាសន៍ក្នុងវេទិកាសាធារណៈស្តីពីថវិកាឆ្នាំ២០១៨កាលពីព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨នៅទីស្តីការក្រសួងថា ប្រាក់ចំណូលនេះគឺបានកើនឡើងកាលពីឆ្នាំ២០១៧ដែលមានត្រឹមតែ១.៤៣៥ដុល្លារ។

លោកបានបន្តទៀតថាទុនបម្រុងអន្តរជាតិរបស់កម្ពុជាក៏មានកំណើនដែរ ពោលគឺកាលពីឆ្នាំ២០១៧ មានទំហំត្រឹមតែ៩.០៥០លានដុល្លារ នឹងកើនដល់១០.៥១៨លានដុល្លារ នៅក្នុងឆ្នាំ២០១៨។ ខណៈដែលអតិផរណាវិញត្រូវបានព្យាករណ៍ថានឹងធ្លាក់ពី៣,៨ភាគរយនៅក្នុងឆ្នាំ២០១៧មកនៅត្រឹម៣,៥ភាគរយនៅក្នុងឆ្នាំនេះ។

លោកបានបន្តទៀតថា ការរក្សាបាននូវកំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ២០១៨នេះ និងការបន្តកំណើនក្នុងឆ្នាំខាងមុខទៀតគឺដោយសារមូលដ្ឋានរឹងមាំ និងការគ្រប់គ្រងបានល្អរបស់រាជរដ្ឋាភិបាលកម្ពុជា។

លោកបានបញ្ជាក់ថា "សេដ្ឋកិច្ចកម្ពុជានៅតែមានកំណើនប្រមាណ៦,៩ភាគរយនៅក្នុងឆ្នាំ២០១៨នេះ ដោយសារមានការប្រែប្រួលលើវិស័យមួយចំនួនដូចជាវិស័យកសិកម្មឧស្សាហកម្ម និងសេវាកម្មនៅតែមានសក្តានុពលខ្ពស់ និងបន្តការរីកចម្រើន"។

លោកបានបន្តថា វិស័យកសិកម្មក្នុងឆ្នាំ២០១៨នេះ គឺនៅមានកំណើនខណៈដែលអង្ករជាវិស័យឈានមុខការផលិតស្រូវក៏មានការកើនឡើងហើយកៅស៊ូ និងដំឡូងមីក៏កំពុងតែមានសក្តានុពលក្នុងការនាំចេញទៅកាន់ទីផ្សារក្រៅប្រទេសផងដែរ។

លោកបានបន្ថែមថា ចំណែកវិស័យឧស្សាហកម្មកាត់ដេរហាក់បីដូចជាមានការថមថយធ្លាក់ចុះបន្តិច ហើយវិស័យមិនមែនកាត់ដេរនៅតែមានសន្ទុះខ្លាំងដូចជាវិស័យម្ហូបអាហារគ្រឿងបង្គុំជាដើមកំពុងតែមានការកើនឡើងខ្លាំង។ ចំពោះវិស័យសំណង់គឺនៅតែមានសន្ទុះ វិស័យសេវាកម្មនៅតែរឹងមាំ ដោយសារតែវិស័យទេសចរណ៍កំពុងមានកំណើនទេសចរកើនឡើងគួរឱ្យកត់សម្គាល់។ ទន្ទឹមនេះសកម្មភាពលក់ដូរ និងដឹកជញ្ជូនក៏នៅតែមានការកើនឡើងដែលសុទ្ធតែជាកត្តាដែលជួយទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ។

លោកបានឱ្យដឹងទៀតថា "រាជរដ្ឋាភិបាលកម្ពុជាមានលទ្ធភាពក្នុងការគ្រប់គ្រងសេដ្ឋកិច្ចមិនឱ្យស្លាប់ និងអាចជួយជំរុញឱ្យសេដ្ឋកិច្ចមានការកើនឡើងដើម្បីស្ថិរភាពសង្គម និងការគ្រប់គ្រងប្រកបដោយកំណើន និងភាពរឹងមាំ"។

លោកបានអះអាងបន្តទៀតថា រហូតមកដល់ពេលនេះកម្រិតនៃការពឹងពាក់ប្រទេសដទៃ កម្ពុជាបានចាប់ផ្តើមកាត់បន្ថយជាបណ្តើរៗពីមួយឆ្នាំទៅមួយឆ្នាំហើយបោះជំហានឈានទៅរកសក្តានុពលនៃការគ្រប់គ្រងលើសេដ្ឋកិច្ចបានដោយខ្លួនឯង។

លោកបានបញ្ជាក់ទៀតថា "កម្ពុជាកំពុងតែមានផែនការកាត់បន្ថយកម្ចីពីបរទេសតាមរយៈការជម្រុញការប្រមូលទុននៅក្នុងស្រុក"។

តាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឲ្យដឹងថា កម្ពុជាកំពុងតែជំពាក់បរទេស គឺមានដូចជាចិន ជប៉ុន ប្រទេសជាមិត្តនានា ស្ថាប័នហិរញ្ញវត្ថុធំៗដូចជា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយប័ណ្ណអន្តរជាតិ... ប្រមាណជា ៧,១ពាន់លានដុល្លារ កាលពីឆ្នាំ២០១៧ ហើយត្រូវព្យាករណ៍ថា នៅឆ្នាំ២០១៨ នេះ បំណុលបរទេសនឹងកើនដល់ទី ៧,៨ពាន់លានដុល្លារ ។

ទាក់ទិននឹងបញ្ហាបំណុលនេះលោកវង្សីវិស្សុត បានមានប្រសាសន៍ថា កម្រិតបំណុលនេះគឺក្នុងស្ថានភាពអាចទ្រទ្រង់បានហើយយើងក៏នៅមានសមត្ថភាពដែលអាចខ្ចីពីបរទេសរកទុនវិនិយោគ នៅកម្ពុជាបានថែមទៀតដែរ ប៉ុន្តែជាទស្សនវិស័យរបស់រាជរដ្ឋាភិបាល គឺយើងកំពុងតែរកវិធីរក្សាតុល្យភាពនេះឲ្យរឹងមាំ ។

លោកបានបន្តទៀតថា យើងនឹងអាចកាត់បន្ថយបំណុលបរទេសនេះតាមរយៈការស្វែងរកការប្រមូលទុនពីក្នុងស្រុក ដោយតាមផ្សារហ៊ុនជាដើម ដោយនៅពេលនេះកំពុងតែរៀបចំ ទីផ្សារ ហ៊ុន តាមអនឡាញ ដោយរំពឹងថា អាចអនុវត្តនៅក្នុងឆ្នាំ២០១៩។

លោកបានបញ្ជាក់ទៀតថា "យើងកំពុងតែរៀបចំគោលនយោបាយថ្មីមួយដែលនឹងកាត់បន្ថយកម្ចីពីបរទេស"។

លោកបន្តទៀតថា នេះហើយ គឺជាគោលនយោបាយដើម្បីធ្វើឱ្យមានសេដ្ឋកិច្ចមួយប្រកបដោយស្ថិរភាពដោយកម្ពុជាត្រូវបង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនបង្កើនតម្លៃបន្ថែមក្នុងសេដ្ឋកិច្ចឱ្យមានចីរភាពដែលផ្តល់កំណើន និងការប្រកួតប្រជែងបន្ថែមទៀត។

ជុំវិញស្ថានភាពនៃសេដ្ឋកិច្ចកម្ពុជានេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍ថា ចង់មើលការរីកចម្រើនរបស់ប្រជាពលរដ្ឋកម្ពុជាសូមមើលការប្រែប្រួលនៃជីវភាពរបស់ប្រជាពលរដ្ឋនៅតាមគ្រួសារ។ សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា ដើម្បីឲ្យឃើញពីការអភិវឌ្ឍន៍របស់កម្ពុជាពិតប្រាកដ សូមក្រឡេកមើលការរីកចម្រើននៅតាមគ្រួសារនីមួយៗនៅក្នុងប្រទេស។

បើតាមការព្យាករណ៍ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៨បានបង្ហាញថា ផលិតផលក្នុងស្រុកសរុបនឹងមានកំណើនប្រមាណ៦,៩ភាគរយ វិស័យកសិកម្ម ២ភាគរយ វិស័យឧស្សាហកម្ម ៨,៦ភាគរយ និងវិស័យសេវាកម្មប្រមាណ ៧,៦ភាគរយ ហើយនៅក្នុងឆ្នាំ២០១៩ខាងមុខ កម្ពុជានឹងអាចរក្សាបានស្ថានភាពប្រហាក់ប្រហែលគ្នានេះ៕

ដោយ អរិយបុត្រ

# យុវវ័យ៖ ១៤កុម្ភៈ ទិវានៃក្តីស្រឡាញ់ គ្រាន់តែជាថ្ងៃបង្ហាញក្តីស្រឡាញ់

ថ្ងៃទី១៤ ខែកុម្ភៈ ទិវានៃក្តីស្រឡាញ់ ឬក៏ Valentine's Day នៅតែជិតជាប់ក្នុងផ្នត់គំនិតនៃយុវវ័យខ្មែរ ដោយគ្មានការផ្លាស់ប្តូរឡើយរហូតដល់ពេលបច្ចុប្បន្ននេះ។

យុវជន គី សេរីវឌ្ឍនៈ បានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនចំពោះថ្ងៃទី១៤ ខែកុម្ភៈនេះថា ចំពោះថ្ងៃទិវានៃក្តីស្រឡាញ់មានន័យថា យើងបង្ហាញនូវភាពស្រឡាញ់របស់យើងទៅកាន់ក្រុមគ្រួសាររបស់យើង ឬក៏អ្នកជាទីស្រឡាញ់របស់យើង ឬក៏ជាបងប្អូន ពូមីង ជាពិសេសមនុស្សដែលយើងស្រឡាញ់ អ្នកម៉ាក់ហើយនិងលោកប៉ារបស់យើង។

យុវតីវ័យជាង២០ឆ្នាំម្នាក់ទៀត គឺ កញ្ញា ផាង មូលីគា បានថ្លែងថា ចំពោះរូបកញ្ញាវា គឺជាទិវារបស់អឺរ៉ុបទេតែវាបានហូរចូលមកស្រុកខ្មែរ ហើយពួកគាត់ក៏បានរៀបចំកម្មវិធីនឹងបានជាច្រើនឆ្នាំមកហើយ។

កញ្ញាបានបញ្ជាក់ថា "ចំពោះទិវានេះ ខ្ញុំយល់ថា ជាទិវាមួយដែលគេផ្តល់ឱកាសឲ្យយុវជន កូន សិស្សនិស្សិត ក៏ដូចជាគូស្នេហ៍ ផ្តល់ឱកាសឲ្យពួកគាត់បង្ហាញពីក្តីស្រឡាញ់ ទៅដល់អ្នកទាំងនោះ...។

រីឯ យុវនារីម្នាក់ទៀត ដែលឈរកម្សាន្តនៅមុខព្រះបរមរាជវាំងចតុមុខ កញ្ញា ស្រីពៅ បានថ្លែងការយល់របស់កញ្ញាថា ទិវានេះកញ្ញាឃើញថាល្អ ហើយថ្ងៃហ្នឹងជាថ្ងៃដែលយើងបង្ហាញពីការស្រឡាញ់របស់យើង ទៅកាន់ម៉ាក់ប៉ា មិត្តភក្តិ ហើយនឹងមនុស្សជាទីស្រឡាញ់ តែវាមិនមែនថ្ងៃដែលគេនាំគ្នា ផ្តោតទៅលើការធ្វើអ្វីមួយមិនល្អ ដូចជាថ្ងៃប្រគល់ខ្លួនប្រាណឲ្យសង្សារអីចឹងនោះទេ ។

កញ្ញាបានបញ្ជាក់ថា "វាមិនមែនជាថ្ងៃចឹងទេ វាគ្រាន់តែជាថ្ងៃដែលយើងផ្តល់ក្តីស្រឡាញ់ឲ្យម៉ាក់ប៉ាយើង បងប្អូនយើងចឹងឯង"។

លោក តុង សុប្រាជ្ញ អ្នកស្រាវជ្រាវបញ្ហាសង្គម បែរជាផ្តោតសំខាន់តែទៅលើផែនការរួមភេទ របស់យុវវ័យនៅថ្ងៃនោះទៅវិញ។ លោក តុង សុប្រាជ្ញ បានថ្លែងថា យុវវ័យមួយចំនួននៅតែមិនទាន់យល់ពីអត្ថន័យថ្ងៃទី១៤ ខែកុម្ភៈ ទិវានៃក្តីស្រឡាញ់ឲ្យបានច្បាស់នៅឡើយ ហើយអ្នកខ្លះនៅតែថាថ្ងៃនេះជាថ្ងៃបូជាខ្លួនប្រាណ ដើម្បីបង្ហាញពីស្នេហ៍ស្មោះជូនដល់ភាគីបុរស ដែលជាសង្សាររបស់ខ្លួន។

យោងទៅតាមការស្រាវជ្រាវ របស់លោក តុង សុប្រាជ្ញ ស្តីពីឥរិយាបទរបស់យុវវ័យនៅថ្ងៃនេះ បានលើកឡើងថា ថ្ងៃទី១៤ ខែកុម្ភៈ ទិវានៃក្តីស្រឡាញ់នៅតែជាថ្ងៃ ដែលភាគីបុរសៗមានផែនការរួមភេទជាមួយនឹងនារីដែលជាដៃគូសង្សាររបស់ខ្លួន។

លោកលើកឡើងថា តាមការស្រាវជ្រាវមានបុរស៤០% បានឆ្លៀតឱកាសយកថ្ងៃទី១៤ ខែកុម្ភៈ ទិវានៃក្តីស្រឡាញ់ លួងលោមនារីជាសង្សារតាមរយៈការទិញផ្កាកុលាប ខ្សែក ចិញ្ចៀន នឹងរបស់មានតម្លៃជាច្រើនផ្សេងទៀត ដើម្បីដោះដូរទៅនឹងការរួមភេទត្រឡប់មកវិញ។

លោក តុង សុប្រាជ្ញ បានថ្លែងដូចនេះថា ក្នុងចំណោមអ្នកដែលមានផែនការរួមភេទនៅថ្ងៃនេះចឹង យើងសួរគាត់មួយទៀតថាប្រសិនបើមិត្តនារីរបស់គាត់មិនយល់ព្រមតើអ្នកនឹងធ្វើដូចម្តេច? ចម្លើយទាំងអស់គឺមាន ៤៧% គាត់នឹងដាក់សម្ពាធទៅនឹងមិត្តនារីរបស់គាត់ ដាក់សម្ពាធយ៉ាងម៉េចតាមរយៈការទិញរបស់ដែលមានតម្លៃ តាមរយៈការបង្ហាញថាបើយើងមិនរួមភេទថ្ងៃនឹងទេ គឺគេមិនស្រឡាញ់គ្នាស្មោះត្រង់ទេ។

លោកបានបន្តថា ចំណុចមួយទៀតគាត់នឹងមានការដើរលេង និយាយរាប់ថា អូសក្រឡាពោលគឺទៅណា ដើរលេងឲ្យបានឆ្ងាយឲ្យបានយូរទៅ រួចគាត់នឹងប្រាប់ថាចូលផ្ទះយប់ពិបាក ដូច្នេះមានតែចូលផ្ទះសំណាក់ ដូច្នេះបានន័យថាបង្ខំតាមរយៈដាក់សម្ពាធពីខាងក្រៅ សេដ្ឋកិច្ច នឹងសេចក្តីស្រឡាញ់របស់គាត់ មិនស្មោះត្រង់។

លោកបានបញ្ជាក់ថា "ត្រង់ចំណុចទាំងនេះហើយដែលយើងមានការកត់សម្គាល់ឃើញថា គាត់អាចមានតែការផ្លាស់ប្តូរនូវឥរិយាបទខាងក្រៅទេ ប៉ុន្តែមិនទាន់ផ្លាស់ប្តូរគោលបំណងផ្លូវភេទរបស់ពួកគាត់នៅឡើយទេបាទ"។

យុវជន គី សេរីវឌ្ឍនៈ ដែលមានវ័យមិនលើសពី២០ឆ្នាំបានលើកឡើងបន្តទៀតថា ជាការពិតណាស់យុវវ័យមួយចំនួនរួមទាំងលោក ផ្ទាល់សុទ្ធតែបានឆ្លងកាត់ភាពជាយុវវ័យ មានសង្សារតែលោកមិនដែលយកទិវានៃក្តីស្រឡាញ់ទៅបំផ្លាញអនាគត គូស្នេហ៍របស់លោកឡើយ រៀងរាល់ឆ្នាំគាត់តែងតែផ្តល់ក្តីស្រឡាញ់ចំពោះតែអ្នកមានគុណ ដោយការជូនបាច់ផ្កាទៅគាត់។

លោក គី សេរីវឌ្ឍនៈ បានបន្តថា មនុស្សទាំងអស់គ្នា ឧទាហរណ៍ឲ្យចំតែម្តងខ្ញុំជាមនុស្សប្រុស តែងតែមានកាមតណ្ហានៅក្នុងខ្លួន ប៉ុន្តែសម្រាប់ថ្ងៃហ្នឹង ប្រសិនបើយើងធ្វើចឹងទៅលើសង្សាររបស់ខ្លួន ឬក៏មនុស្សស្រីដទៃទៀត វាជាមើលងាយធំបំផុតព្រោះថា ខ្ញុំក៏មានក្រុមគ្រួសារជាមនុស្សស្រីដែរ ដូចជា បងស្រីខ្ញុំ ឬក៏ម៉ាក់របស់ខ្ញុំ បើខ្ញុំយកថ្ងៃហ្នឹងទៅបំពានទៅលើនារីភេទដទៃទៀត គឺវាមិនសមរម្យនោះទេ។

លោកបានបញ្ជាក់ថា "នរណាក៏មានបេះដូង នរណាគេក៏មានចិត្តដែរ បើយើងយកថ្ងៃហ្នឹងទៅបំផ្លាញអនាគតរបស់កូនស្រីគេ នេះជាការមើលងាយដ៏ធំបំផុត ហើយនេះជាការមើលងាយដ៏ធំបំផុតនៅក្នុងសង្គមរបស់យើង"។

ក្រឡេកមកមើលយុវតីមួយរូបទៀត គឺ កញ្ញា ផាន់ ម៉ូលីតា បានបញ្ជាក់ថា ថ្ងៃទី១៤ ខែកុម្ភៈ បានស្ថិតនៅក្នុងផ្នត់គំនិតរបស់យុវវ័យខ្មែរភាគច្រើនរួចទៅហើយ រហូតធ្វើឲ្យមានការយល់ច្រឡំសម្រាប់ថ្ងៃមួយនេះ។ កញ្ញា ផ្ទាល់ខ្លួនរូបនេះ បានបញ្ជាក់ថា ការយល់ច្រឡំថ្ងៃទិវានៃក្តីស្រឡាញ់ថាជាថ្ងៃបុណ្យសង្សារ បានធ្វើឲ្យយុវតី ឈានទៅការធ្វើអត្តឃាត និងរហូតដល់ បាត់បង់ជីវិតជាដើម។

កញ្ញាបានបន្តទៀតថា "ខ្ញុំគិតថាគំនិតមួយហ្នឹង នៅតែគិតបែបហ្នឹង ជិតនៅក្នុងគំនិតរបស់យុវតី ស្រុកខ្មែរទៀត ខ្ញុំគិតថាវប្បធម៌ នារីរក្សាព្រហ្មចារីហ្នឹង នឹងត្រូវបាត់បង់ ហើយនឹងមានបញ្ហាជាច្រើនដែរនឹងកើតមាន ដូចជា ធ្វើអត្តឃាត ការខូចចិត្ត លះបង់ការសិក្សា"។

លោក តុង សុប្រាជ្ញ បានធ្វើការសង្កត់ធ្ងន់ បញ្ហាអវិជ្ជមានរបស់យុវវ័យ ដែលប្រឡូកនឹងការរួមភេទនៅថ្ងៃបុណ្យនៃក្តីស្រឡាញ់ថា ផលប៉ះពាល់រួមមានការមានផ្ទៃពោះ ប្រឈមទៅនឹងការឆ្លងជំងឺកាមរោគ និងឈានរហូតដល់ការធ្វើអត្តឃាតដែលផ្តើមចេញពីការមិនទទួលខុសត្រូវរបស់ភាគីខាងបុរស។

លោក តុង សុប្រាជ្ញ បានស្នើទៅដល់យុវវ័យថា កុំមានការយល់ច្រឡំ ទៅលើអត្ថន័យ ថ្ងៃទី១៤ ខែកុម្ភៈ ហើយសូមឲ្យបុរសៗកុំធ្វើការឆ្លៀតឱកាស និងកេងចំណេញ យកថ្ងៃនោះបំផ្លាញអនាគតរបស់នារីភេទ ត្រូវគិតថា យើងមានម្តាយ មានបងប្អូន ជាស្ត្រីភេទ ជាភេទអតិភាព ដែលមនុស្សគ្រប់គ្នាត្រូវគោរពនិងឲ្យតម្លៃ៕

*ដោយ សុផានិត*




ថតដោយ: សម្បត្តិ

# កម្មករនិងកម្មការិនីផ្សេងៗក៏ចង់ជួបសម្តេចតេជោ ហ៊ុន សែន ផងដែរ

ភាពស្និទ្ធស្នាលរវាងសម្តេចតេជោ ហ៊ុន សែន និងបងប្អូនកម្មករនិងកម្មការិនីរោងចក្រកាត់ដេរ កំពុងតែធ្វើឲ្យបងប្អូនកម្មករនិងកម្មការិនីខាងសំណង់និងវិស័យនានាក្រៅប្រពន្ធមួយចំនួនចង់ជួប និងសំណេះសំណាលជាមួយនឹងសម្តេចដូចជា កម្មករនិងកម្មការិនីរោងចក្រកាត់ដេរផងដែរ។

ថ្លែងនៅការដ្ឋានសំណង់មួយកន្លែង នៅខេត្តព្រះសីហនុ កន្លែងដែលសំណង់អាគារខ្ពស់ៗប្រមាណជា២០ គម្រោងកំពុងតែដុះឡើងនោះ លោក វណ្ណារ៉េត ជាកម្មករសំណង់មួយរូបនៅការដ្ឋានមួយ បានថ្លែងពេលសម្រាកទទួលទានអាហារថ្ងៃត្រង់របស់ខ្លួនថា បើតាមព័ត៌មាន តាមហ្វេសបុកអីឃើញតែសម្តេចតេជោ ហ៊ុន សែន ជួបតែជាមួយនឹងកម្មករនិងកម្មការិនីរោងចក្រកាត់ដេរ តែមិនដែលបានឃើញជួបកម្មករសំណង់អីសោះ។

វណ្ណារ៉េត បាននិយាយសង្កត់ធ្ងន់ថា "ឃើញ សម្តេច ហ៊ុន សែន ជួបជាមួយតែកម្មករកាត់ដេរតែរហូត ឯកម្មករសំណង់ដូចជាពួកខ្ញុំ ដូចជាមិនដែលបានឮសោះ"។

នៅក្នុងអំឡុងពេលនោះ មិត្តភក្តិ របស់វណ្ណារ៉េតម្នាក់ ដែលបានប្រាប់ឈ្មោះថា ដេត បានលូកមាត់ បន្ថែមថា កម្មករដូចតែគ្នា សម្តេច( សម្តេចតេជោ ហ៊ុន សែន )គួរតែជួបពួកគេផង ។

ដេតបានបន្ថែមបន្តិចថា លោកក៏ចង់សែលហ្វី ជាមួយនឹងសម្តេចនឹងគេដែរ ពីព្រោះឃើញតែតាម ហ្វេសបុក ដែលសង្សាររបស់គេបានចែករំលែក ពេលសម្តេចជួបជាមួយនឹងនាង កាលពីពេលថ្មីៗនេះ...។

ដេត បានបញ្ជាក់ថា "សង្សារខ្ញុំជាកម្មករកាត់ដេរនៅស្អី (ខេត្តកំពង់ស្ពឺ) គេបានថតសែលហ្វីបង្ហោះលាន់ហើយ ប៉ុន្មានថ្ងៃមុននេះ ដូច្នេះខ្ញុំចង់សែលហ្វីជាមួយនឹងសម្តេច នឹងគេដែរ"។

ថ្លែងនៅលើរថយន្តក្រុង ពីភ្នំពេញទៅខេត្តព្រះសីហនុ កញ្ញា រីដា អាយុ ២៤ ឆ្នាំ គឺជាអ្នកគិតលុយ នៅសណ្ឋាគារមួយនៅខេត្តព្រះសីហនុ បានឲ្យដឹងថា នាងនិងក្រុមការងារ ព្រមទាំងកម្មករ អនាម័យនិងសំអាតបន្ទប់ ក៏ចង់ជួបសម្តេចនឹងគេបានម្តងដែរ។

រីដា បានបន្តថា សម្រាប់នាង គឺធ្លាប់ជួបសម្តេចបានម្តងដែរពេលដែលទទួលសញ្ញាបត្រ ប៉ុន្តែ បងប្អូនកម្មករអនាម័យសំអាតបន្ទប់ និងបុគ្គលិកដែលបម្រើការនៅសណ្ឋាគារជាមួយគ្នា ក៏ធ្លាប់និយាយធ្លាប់លេងសើចខ្លះដែរពេលដែលគេទទួលព័ត៌មានផ្សេងៗពេលសម្តេចជួយកម្មករនិងកម្មការិនីនៅតាមរោងចក្រកាត់ដេរនានានៅក្នុងប្រទេស ។

រីដា បានបញ្ជាក់ថា "ជួនកាលគេ (កម្មករ និងកម្មការិនីរួមការងារ)និយាយលេងថា កម្មករដូចជាពួកគាត់អីចឹង (កម្មករអនាម័យ និងសំអាតបន្ទប់) ប្រហែលគេមិនឲ្យជួបសម្តេចទេមើលទៅ"។

នេះគឺជាអារម្មណ៍របស់បងប្អូនកម្មករនិងកម្មការិនី នៅក្នុងវិស័យផ្សេងៗក្រៅពីរោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជា ខណៈដែលមកដល់ពេលនេះ សម្តេចតេជោ ហ៊ុន សែន បានជួបជាមួយនឹងក្រុមប្រជាពលរដ្ឋផ្សេងៗរួចរាល់ហើយដែរ ដូចជា កម្មករជាក់ស៊ីក្លូ កម្មករ និងកម្មការិនីកាត់ដេរ ក្រុមក្មេងកំព្រា ក្រុមប្រជាពលរដ្ឋដែលមាននិន្នាការសាសនា ដូចជាគ្រីស្តសាសនា និងអ៊ីស្លាមជាដើម។

គួរបញ្ជាក់ថាចាប់តាំងពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧ មកសម្តេចតេជោ ហ៊ុន សែន បានជួបសំណេះសំណាលជាមួយកម្មករនិយោជិតក៏ដូចជាប្រធានរដ្ឋបាលប្រធានផ្នែកប្រធានក្រុម និងជំនួយការ រោងចក្រសហគ្រាសនានា បានចំនួន២៧ លើករួចមកហើយ។ ក្នុងនោះមានកម្មករនិយោជិតសរុប ជាង៣០ ម៉ឺននាក់ហើយបានជួបសំណេះសំណាលដោយផ្ទាល់ជាមួយសម្តេចប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

សម្តេចតេជោហ៊ុនសែនបានហៅការអញ្ជើញចុះជួបដោយផ្ទាល់របស់សម្តេចជាមួយកម្មករនិយោជិតនេះមិនមែនជារឿងចែដន្យឡើយ តែជាការជួបសំណេះសំណាលដើម្បីជំរុញគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យឧស្សាហកម្មហើយក៏ដើម្បីដឹងពីសុខទុក្ខរបស់កម្មករនិយោជិត និងដោះស្រាយបញ្ហាប្រឈមរបស់ពួកគេផងដែរ។ ជាការកត់សម្គាល់គ្រប់ជំនួបរបស់សម្តេចតេជោ ហ៊ុនសែន ជាមួយកម្មករ កម្មការិនីទទួលបានការគោរពស្រឡាញ់ជាខ្លាំងពីសំណាក់កម្មករ កម្មការិនីហើយពួកគេក៏បានព្យាយាមថតរូបជាមួយសម្តេចតេជោហ៊ុនសែនដើម្បីទុកជាអនុស្សាវរីយ៍។ ក្រុមកម្មករកម្មការិនីបានហៅដំណើរសម្តេចតេជោ ហ៊ុនសែន ចុះជួបពួកគេដោយផ្ទាល់នេះគឺជាការយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះការរស់នៅ និងការបម្រើការងាររបស់ពួកគេពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

តាមរយៈជំនួបដោយផ្ទាល់ជាបន្តបន្ទាប់នេះសម្តេច តេជោ នាយករដ្ឋមន្ត្រីបានតម្កល់ប្រយោជន៍ប្រជាពលរដ្ឋជាធំដោយបានសម្រេចផ្តល់ជាកញ្ចប់អត្ថប្រយោជន៍ជាច្រើនសម្រាប់បងប្អូនកម្មករនិយោជិតដែលរួមមានដូចជា៖អនុញ្ញាតឲ្យកម្មករនិយោជិតមកពីគ្រប់វិស័យជិះរថយន្តក្រុងរបស់សាលារាជធានីភ្នំពេញដោយឥតគិតថ្លៃរយៈពេល២ឆ្នាំ ចាប់ពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧ ដល់២០ ខែសីហា ឆ្នាំ២០១៩។ ចាប់ពីខែមករា ឆ្នាំ២០១៨ ថៅកែរោងចក្រ សហគ្រាស ដែលជាសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គមត្រូវទទួលរ៉ាប់រងរាល់សេវាគាំពារសុខភាពរបស់កម្មករនិយោជិត។ ការសម្រេចថ្មីនេះ ធ្វើឲ្យកម្មករនិយោជិតចំណេញប្រាក់ប្រមាណ ៨០០០រៀលទៅ១៣០០០រៀលក្នុងមួយខែ។ កម្មករនិយោជិតមកពីគ្រប់វិស័យទាំងអស់អាចចូលពិនិត្យ និងព្យាបាលជំងឺនៅមន្ទីរពេទ្យរដ្ឋដោយឥតគិតថ្លៃ។ ចាប់ពីឆ្នាំ២០១៨ នេះតទៅរាជរដ្ឋាភិបាលក៏នឹងឧបត្ថម្ភថវិកាដល់កម្មការិនីនៅពេលពួកគេសម្រាលកូនផងដែរ។ ក្នុងនោះអ្នកសម្រាលកូន១ទទួលបានប្រាក់ឧបត្ថម្ភ៤០ម៉ឺនរៀល សម្រាលកូនភ្លោះពីរទទួលបានប្រាក់ឧបត្ថម្ភ៨០ម៉ឺនរៀល ហើយអ្នកសម្រាលបានកូនភ្លោះ៣ ទទួលបានប្រាក់ឧបត្ថម្ភ១លាន២០ម៉ឺនរៀល។ ជំរុញឲ្យមានការដំឡើងប្រាក់ឈ្នួលទាបបំផុត១៧០ដុល្លារនៅឆ្នាំ២០១៨។

ហាមមិនឲ្យមានការដំឡើងថ្លៃឈ្នួលផ្ទះ ឬបន្ទប់នៅក្នុងឆ្នាំ២០១៨។ កម្មការិនីមានផ្ទៃពោះត្រូវបានសម្រេចឲ្យចេញមុនម៉ោងធ្វើការយ៉ាងតិច១៥នាទី ហើយនៅពេលសម្រាលត្រូវបានអនុញ្ញាតឲ្យឈប់សម្រាករយៈពេល៣ខែជាមួយអត្រាប្រាក់ខែ១២០ភាគរយ។ ចាប់ពីឆ្នាំ២០១៩ កម្មករនិយោជិតមានប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការ។ ប្រាក់នេះសម្រាប់ជួយដោះស្រាយជីវភាពកម្មករនិយោជិតនៅពេលពួកគេចាប់បម្រើការងារលែងកើត៕

*ដោយ អរិយបុត្រ*



ថតដោយៈ សហការី ស៊ីអេសស៊ី

# កិច្ចព្រមព្រៀងពីរ រវាងកម្ពុជា-ចិនត្រូវបានពលរដ្ឋកម្ពុជាចាប់អារម្មណ៍




រូបថតដោយពី AKP

កម្ពុជានិងចិនបានចុះហត្ថលេខាលើឯកសារសំខានៗចំនួនរហូតដល់ទៅ១៩ ដែលអាចមានទឹក ប្រាក់រាប់សិបលានដុល្លារ កាលពីថ្ងៃទី១១ ខែមករា នៅក្នុងអំឡុងពេលទស្សនកិច្ចរបស់លោក នាយករដ្ឋមន្ត្រីចិននៅកម្ពុជា ប៉ុន្តែគម្រោងចំនួន ២ ដែលប្រជាពលរដ្ឋមួយចំនួនចាប់អារម្មណ៍។

លោក រុន ចាន់ណា ជាប្រជាពលរដ្ឋរាជធានីភ្នំពេញមួយរូប បានឲ្យដឹងថា គម្រោងដែលបានចុះ ហត្ថលេខា គឺសុទ្ធតែសំខាន់ ប៉ុន្តែលោកចាប់អារម្មណ៍មានពីរ គឺគម្រោងកសាងផ្លូវល្បឿនលឿន ភ្នំពេញ និងខេត្តព្រះសីហនុ និង គម្រោងកសាងព្រលានយន្តហោះភ្នំពេញថ្មី នៅខេត្តកណ្តាល។

លោកបានបន្តទៀតថា គម្រោងនេះគឺជាគម្រោងថ្មី ដែលគួរឲ្យចាប់អារម្មណ៍បំផុត ខណៈគម្រោង ផ្សេងៗទៀត ដូចជាធ្លាប់ឮ ធ្លាប់បានដឹងថា ចិនគេជួយច្រើន។

លោកបានបញ្ជាក់ថា "ការជំនួយឥតសំណង ជំនួយកសិកម្ម ជំនួយកសាងនេះកសាងនោះ គម្រោងពាណិជ្ជកម្ម គឺធ្លាប់ឮចិនជួយច្រើន តែអារឿងផ្លូវល្បឿនលឿន និងព្រលានយន្តហោះថ្មីនេះបានដូចជាចាប់អារម្មណ៍"។

លោក ជា ប្រាថ្នា ជាអ្នកប្រកបរបរលក់ដូរមួយរូប នៅខេត្តព្រះសីហនុ បានឲ្យដឹងថា មិនចាំអស់ទេ គម្រោងដែលចិនជួយហើយចុះហត្ថលេខាកាលពីពេលថ្មីៗនេះ តែដូចជាស្រពិចស្រពិល រឿងកសាងផ្លូវ express way( ផ្លូវល្បឿនលឿន ) ពីភ្នំពេញមកខេត្តព្រះសីហនុ និងគម្រោងកសាងព្រលានយន្តហោះថ្មីនៅភ្នំពេញ ។

លោកបានបញ្ជាក់ថា "គ្មានពេលបានអាន បានស្តាប់ច្រើននឹងគេទេ បានជាខ្ញុំមិនសូវដឹងអីនឹងគេ តែឮគេជជែកគ្នា នៅតាមតុកាហ្វេគុយទាវ ពីរឿងផ្លូវ express នេះ និងអាស្អីអី...ព្រលានយន្តហោះនេះឯង "។

មន្ត្រីរាជការមួយរូប ដែលប្រាប់ឈ្មោះត្រឹមតែថា ទេវិន បានឲ្យដឹងថា ចាំវាមិនអស់ទេ ដោយសារ តែចិនគាត់ជួយច្រើន តែអាថ្មីបំផុតហើយក្តៅហ៊ុយៗ គឺឯកសារទាក់ទងនឹងផ្លូវល្បឿនលឿន និងព្រលានយន្តហោះនេះហើយ ដោយសារតែវាធំមានទឹកប្រាក់រាប់សិបលានដុល្លារ។

គួររំលឹកថា ឯកសារដែលមន្ត្រីកម្ពុជានិងចិនបានចុះហត្ថលេខាកាលពីថ្ងៃទី១១ ខែមករា ទាំង១៩ គឺមានទាក់ទង នឹងគម្រោងពង្រីកផ្លូវ គម្រោងកសាងមន្ទីរពេទ្យ គម្រោងទាក់ទងនឹងអភិវឌ្ឍន៍ កសិកម្ម ពាណិជ្ជកម្ម គម្រោងអប់រំសុខាភិបាល អគ្គិសនី... ហើយគម្រោងដែលពលរដ្ឋចាប់អារម្មណ៍ខាងលើ គឺមានឈ្មោះផ្លូវការថា កិច្ចព្រមព្រៀងសម្បទាន សម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ និងគម្រោងដែលចុះហត្ថលេខា ដោយ លោក ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ជាមួយនឹង លោក លាវ ឈីថាវ ប្រធានក្រុមហ៊ុនសំណង់គមនាគមន៍ចិន ដោយឡែក គម្រោងដែល ពលរដ្ឋ ចាប់អារម្មណ៍មួយទៀត គឺកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីកិច្ចសហប្រតិបត្តិការហិរញ្ញប្បទាន សម្រាប់គម្រោងអាកាសយានដ្ឋានភ្នំពេញថ្មី ប្រទេសកម្ពុជា ដែលចុះហត្ថលេខា ដោយ លោក ពុង ឃាវសែ ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនវិនិយោគទុនអាណិកជនកម្ពុជា និងលោក ហ៊ូ ហ៊្វយប៉ាង ប្រធានធនាគារអភិវឌ្ឍន៍ចិន។

គម្រោងកសាងផ្លូវល្បឿនលឿនភ្នំពេញ - ខេត្តព្រះសីហនុ មិនទាន់ដឹងថា មានតម្លៃពិតប្រាកដ ប៉ុន្មាននោះទេ ប៉ុន្តែបើយោងទៅតាមពង្រាងផែនការដែលក្រសួងសាធារណការនិងដឹកជញ្ជូនធ្លាប់បង្ហើប បានឲ្យដឹងថា គម្រោងនេះ មានទឹកប្រាក់ប្រមាណជា ១.៦០០ លានដុល្លារ ដោយផ្លូវនេះ នឹងត្រូវកសាងនៅក្នុងប្រវែងប្រមាណជា ១៩០ គីឡូម៉ែត្រដោយមានទទឹង ២៥ ម៉ែត្រ ហើយសាងសង់នៅក្រោមលក្ខខណ្ឌ BoT ។

ដោយឡែក តាមឯកសារដែលបានបែកធ្លាយដល់អ្នកសារព័ត៌មានទាក់ទងនឹងគម្រោងកសាងព្រលានយន្តហោះភ្នំពេញថ្មីនោះ គឺមានទឹកប្រាក់ ១.៥០០លានដុល្លារ។ ហើយ ទីតាំងដែលត្រូវអភិវឌ្ឍន៍ព្រលានយន្តហោះភ្នំពេញថ្មី នោះគឺមានទីតាំងនៅក្រុងតាខ្មៅ និងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានផ្ទៃដីរហូតដល់២.៦០០ហិកតា។

យោងតាមលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ផ្ញើទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោកអូន ព័ន្ធមុនីរ័ត្ន និងលោក ម៉ៅ ហាវណ្ណាល់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល គម្រោងនេះគឺ នឹងអភិវឌ្ឍន៍ដោយក្រុមហ៊ុន "ខេមបូឌា អ៊ែរផត អ៊ិនវេសមិន" ដែលក្រុមហ៊ុននោះ គឺគ្រប់គ្រងភាគច្រើន ដោយលោកពង្ស ខៀវសែក្នុងនោះទឹកប្រាក់ ១.១០០ លានដុល្លារ ជាកម្ចីពីធនាគារបរទេស និង ២៨០លានដុល្លារជារបស់ក្រុម លោក ពុង ខៀវសែ ហើយដើមទុនចុះបញ្ជីមានរហូតដល់ ១២០លានដុល្លារអាមេរិក។

ទាក់ទងនឹងគម្រោងកសាងផ្លូវល្បឿនលឿន គឺកន្លងមកមិនសូវជាមានពាក្យចចាមអារ៉ាមទេ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានបង្ហើបប្រាប់អំពីគម្រោងនេះជាបន្តបន្ទាប់កាលពី ប៉ុន្មានឆ្នាំមុន ជាពិសេសគឺចាប់ពីឆ្នាំ២០១៦ មក ប៉ុន្តែដោយឡែកសម្រាប់គម្រោងកសាងព្រលានយន្តហោះភ្នំពេញថ្មីនោះវិញ គឺមានពាក្យចចាមអារ៉ាមច្រើនអំពីទីតាំង ដោយដំបូង ត្រូវគេល្បីថា អាចមានទីតាំង នៅនឹងខេត្តកំពង់ស្ពឺ ក្រោយមកក៏ផ្ទុះព័ត៌មានថានៅ អាកាសយានដ្ឋានខេត្តកំពង់ឆ្នាំង ដែលទុកចោលក្រោយពីកសាងឡើងកាលពី សម័យប៉ុលពត និងក្រោយមកទៀត ក៏លេចឮព័ត៌មានថា នៅខេត្តកំពង់ស្ពឺវិញ ដល់បច្ចុប្បន្នស្រាប់តែមានទីតាំងនៅខេត្តកណ្តាល ៕

*ដោយ សុផានិត និងអរិយបុត្រ*

# វិស័យកសិកម្មនៅក្នុងប្រទេសថៃត្រូវបានគេអះអាងថា កំពុងតែដើរថយក្រោយ

វិស័យកសិកម្មនៅក្នុងប្រទេសថៃ ត្រូវបានគេអះអាងថា កំពុងតែដើរថយក្រោយ បើប្រៀបធៀប នឹងបណ្តាលប្រទេសនានា នៅក្នុងតំបន់អាស៊ាន ជាពិសេសគឺវៀតណាម។

នៅក្នុងការប្រកួតប្រជែងនៅក្នុងតំបន់ វិស័យកសិកម្ម របស់ប្រទេសថៃ គឺបាន បង្ហាញនូវសញ្ញានៃភាពទន់ខ្សោយធៀប នឹងអ្នកប្រកួតប្រជែងផ្សេងៗនៅក្នុងតំបន់ ដោយនៅពេលនេះ សមត្ថភាព ផលិតនិង ប្រមូលផលនៅប្រទេសផ្សេងៗ គឺកាន់តែប្រសើរទិន្នផលក៏កាន់តែប្រកួតប្រជែង។

វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍ថៃបាន ព្រមានថា ធៀបនឹងវៀតណាម កសិកម្មនៅថៃ គឺមានសញ្ញា នៃភាពទន់ខ្សោយ ដោយ វៀតណាម គឺបានចាប់ផ្តើមសមត្ថភាព ប្រកួតប្រជែងកាន់តែខ្លាំងនៅក្នុងតំបន់។

វិទ្យាស្ថាននេះ បានព្រមានថា ការបើកចំហរទីផ្សារ នៅក្រោមកិច្ចព្រមព្រៀងកសិកម្ម ដែលជាផ្នែក មួយនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន កំពុងតែដាក់សំពាធមកលើ សមត្ថភាពផលិតកម្មកសិកម្មរបស់ថៃ។

តាមកិច្ចព្រមព្រោងផ្សេងទៀតដែល បានកំណត់ ដោយបណ្តាមេដឹកនាំអាស៊ាន ប្រជាជាតិអាស៊ានទាំងអស់គឺចាប់ផ្តើមកាត់ បន្ថយពន្ធនាំចូល ចាប់ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១៥ លើកលែងតែផលិតផលមួយ ចំនួន ដែលត្រូវការពារ ប៉ុន្តែនៅឆ្នាំ២០១៨ នេះ អ្វីៗនឹងត្រូវបញ្ចប់។

ផលិតផលកសិកម្មដែលរំពឹងថា កំពុងតែទន់ខ្សោយនោះគឺ រួមមានដំណាំអំពៅ យកស្ករ និងផលិតកម្មស្ករ កសិកម្មដាំ បន្លែ និងចិញ្ចឹមសត្វដោយមិនមានសារជាតុគីមី បញ្ហាផលិតកម្មអាហារសមុទ្រ អាហារសត្វ និង ផលិតផលទឹកដោះគោ។ ម៉្យាងវិញទៀតប្រភពដដែលក៏បានព្រមានផងដែរ ថា ថៃក៏នៅមិនទាន់អាចកែលំអរផលិតកម្មស្រូវ និងផលិតកម្មដំណាំដូងប្រេងរបស់ខ្លួននៅឡើយផងដែរ។

អ្នកជំនាញការកំពុងតែជំរុញឲ្យថៃគិតគូរឡើងវិញនូវបច្ចេកវិទ្យាកសិកម្ម ក៏ដូចជាធនធានមនុស្ស ខណៈដែលអ្នកជំនាន់មុនកំពុងតែចូលនិវត្តន៍។ ក្រៅពីនេះ ថៃក៏ត្រូវតែគិតគូរទៅលើអ្នកកសិកម្មវ័យឆ្លាតផងដែរ។

គួររំលឹកថា សមត្ថភាពនាំចេញផលិតផលកសិកម្មរបស់អាស៊ានទាំងមូល បានឡើងពី ៣,១ពាន់ លានដុល្លារកាលពីឆ្នាំ ២០០១ ដល់២៨,៤ ពាន់លានដុល្លារនៅ ឆ្នាំ២០១៥ ហើយការនាំចូលផលិតផលកសិកម្មវិញ គឺកើនពី ២,៧ ពាន់លាននៅ ឆ្នាំ២០០១ ទៅដល់២២,១ពាន់លានដុល្លារ នៅឆ្នាំ ២០១៥៕

# "ភាពធន់និងការច្នៃប្រឌិត" គឺជាប្រធានបទសម្រាប់អាស៊ានឆ្នាំនេះ

ក្រោយពេលដែលសិង្ហបុរី បានក្លាយជា ប្រធានអាស៊ានប្តូរវេនអាស៊ានជាផ្លូវការនាឆ្នាំ២០១៨ថ្មីៗនេះ ប្រធានបទដែលលោក លី សៀនឡុង នាយករដ្ឋមន្ត្រីនៃប្រទេសនេះ ប្រកាន់យកសម្រាប់ដឹកនាំ អាស៊ាន នោះ គឺ "ភាពធន់ និងការច្នៃប្រឌិត"។

ជុំវិញប្រធានបទនេះ អ្នកវិភាគមួយចំនួនបានចាត់ទុកថា នេះគឺជាគំនិតដ៏មាន សុទិដ្ឋិនិយមមួយសម្រាប់តំបន់ ប៉ុន្តែសិង្ហបុរី គឺត្រូវការនូវកិច្ចសហប្រតិបត្តិការពេញទំហឹងពីគ្រប់ប្រទេសសមាជិក ទាំងអស់ ក្រោយពេលដែលទិដ្ឋភាពនយោបាយនៅ ក្នុងតំបន់និងពិភពលោក បានផ្លាស់ប្តូរជា ច្រើនកាលពីឆ្នាំទៅ ក្រោយពេលដែល លោក ដូណាល់ ត្រាំ ចូលកាន់តំណែងការ ចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប។

ទិដ្ឋភាពនយោបាយតំបន់ និងពិភពលោកនេះ គឺជាចំណុចប្រឈមមួយរបស់ អាស៊ាន ដោយសារតែនេះ គឺជានិន្នាការ ដែលពិភពលោក កំពុងតែដើរតម្រង់ទៅ រកប្រេកនៃការដឹកនាំតាមបែបឯកតោភាគីនិយម។ ការសម្រេចចិត្តរបស់លោក ដូណាល់ ត្រាំ នៅក្នុងការដកថយចេញពី កិច្ចព្រមព្រៀងពាណិជ្ជកម្ម ភាពជាដៃគូ នៃអន្តរប៉ាស៊ីហ្វិក ដែលប្រទេសអាស៊ាន ជាច្រើនបានចូលរួម បាននាំឲ្យមាននូវការ ផ្លាស់ប្តូរហេ្គមសេដ្ឋកិច្ចតំបន់។

នៅក្នុងបរិបទតំបន់ រឿងសេដ្ឋកិច្ច រឿងវិបត្តិនយោបាយនៅក្នុងប្រទេសមួយ ចំនួន រឿងបញ្ហាសិទ្ធិមនុស្សជាពិសេសគឺ រឿងរ៉ាវជនភាគតិចរ៉ូហ៊ីងយ៉ាងនៅមីយ៉ាន់ម៉ា គឺសុទ្ធតែជារឿងឈឺក្បាលសម្រាប់តំបន់។

នេះគឺជារឿងរ៉ាវត្រួសៗដែលអាចនឹង ប៉ះពាល់ដល់អារម្មណ៍របស់ពលរដ្ឋអាស៊ាន នៅក្រោមការ ដឹកនាំរបស់សិង្ហបុរី នៅឆ្នាំ ២០១៨ ប៉ុន្តែគេមានជំនឿថា តំបន់សេដ្ឋកិច្ចសេរី ដែលអាស៊ានបានដាក់ចេញ កាលពីឆ្នាំ១៩៩២ និងការអនុម័តសហគមន៍សេដ្ឋកិច្ចអាស៊ានកាលពីឆ្នាំ២០០៧ និងសមាហរណកម្មអាស៊ាន នៅឆ្នាំ២០១៥ គឺជាទស្សនដ៏មានសុទិដ្ឋិនិយមមួយរបស់ អាស៊ាន៕

# អាស៊ានកំពុងតែបោះជំហានចូលឆ្នាំទី៥១ របស់ខ្លួនហើយណា !

អាស៊ានចូលឆ្នាំ២០១៨នេះ បានបោះជំហានចាកចេញពី៥០ ឆ្នាំរបស់ខ្លួន សន្សឹមៗ ដើម្បីឈានមកឆ្នាំទី៥១។ ប៉ុន្តែ គេនៅមិនទាន់ដឹងទេថា តើឆ្នាំទី៥១ នេះ អាស៊ាននឹងប្រឈមមុខនឹងអ្វីខ្លះនោះទេ ?

៥០ឆ្នាំកន្លងមក អាស៊ានបានប្រឈម មុខខ្លាំងនឹងបញ្ហាប្រឈមជាច្រើន រួមទាំង បញ្ហាជម្លោះព្រំដែន រវាងសមាជិក និង សមាជិក បញ្ហាលទ្ធិប្រជាធិបតេយ្យ បញ្ហាទំនាស់ដែនដីរវាងសមាជិកអាស៊ាន និង មហាអំណាចចិន បញ្ហានៃការប្រទាញប្រទង់គ្នាដណ្តើមឥទ្ធិពលរវាងអាមេរិក និង ចិន បញ្ហាសមាហរណកម្ម រវាងអាស៊ាន ចាស់ និងអាស៊ានថ្មី ប៉ុន្តែទោះបីជាយ៉ាង ណាក៏ដោយ នៅក្នុងឋានៈជាប្រជាជាតិ មួយនៅអាស៊ាន យើងខ្ញុំសង្ឃឹមថា អាស៊ាន នឹងរួមគ្នាជំនះគ្រប់ឧបសគ្គ ហើយក្លាយ ទៅជាតំបន់មួយ ដែលមានសហប្រតិបត្តិការល្អៗ សេដ្ឋកិច្ចរីកចម្រើន ស្តង់ដារជីវភាពមានការកែសម្រួល ហើយនឹងបន្តរីកចម្រើនទាំងអស់គ្នាដោយស្មើភាព ដោយ គ្មានការរើសអើង។

ជាការពិត អាស៊ានបានត្រូវបង្កើតឡើង នៅក្នុងឆ្នាំ១៩៦៧ នៅក្នុងពេលដែល ពិភពលោកកំពុងតែកើនឡើងកំដៅ នៅ សម័យសង្គ្រាមត្រជាក់ ដោយសមាជិក អាស៊ានចាស់សម័យនោះអាចបង្កើតអាស៊ានឡើង ដើម្បីតែហេតុផលនយោបាយ ដើម្បីឈ្នះសង្គ្រាមត្រជាក់ ដោយយក មូលធននិយមមកគ្រប លើលទ្ធិកុម្មុយនីស្ត ប៉ុន្តែអាស៊ានសម័យនេះ គឺខុសពីសម័យ នោះ ដោយប្រទេសសមាជិកខ្លះ គឺនៅតែ ជារដ្ឋដែលមានគោលនយោបាយបក្សតែ មួយ នឹងដឹកនាំតាមលទ្ធិកុម្មុយនីស្ត ប៉ុន្តែ អាស៊ាននិយាយតែ ពីកិច្ចសហប្រតិបត្តិការ សមាហរណកម្ម ជំរុញកំណើនសេដ្ឋកិច្ច និងសង្គម លើកកម្ពស់កម្រិតជីវភាព ពលរដ្ឋនៅក្នុងតំបន់ ។

ជាការពិតទំនាស់ប្រហែលមិនងាយស្រួលនឹងដោះស្រាយទេ ឧទាហរណ៍ដូច ជាករណីទំនាស់នៅសមុទ្រចិនខាងត្បូង បញ្ហាប្រេះស្រាំផ្នែកសង្គមរវាងក្រុមអ្នកពុទ្ធ សាសនា និងក្រុមជនជាតិភាគតិចមូស្លីមរ៉ូហ៊ីងយ៉ានៅភូមា បញ្ហាកំណត់ព្រំដែនរវាង រដ្ឋសមាជិក។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ ដោយយើងខ្ញុំសង្ឃឹមថា អាស៊ាននៅក្នុង អំឡុងពេល ៥០ឆ្នាំ ទៅមុខទៀតនេះ នឹង ព្យាយាមដោះស្រាយបញ្ហាទាំងនេះ ហើយ រួមគ្នារិះគិតពីរឿងសុខដុមនីយកម្មអាស៊ាន សម្រាប់តំបន់មួយដែលមានប្រជាពលរដ្ឋ ប្រមាណជា៦០០លាននាក់វិញ។ បើទោះបី ជាវាមិនមែនជារឿងងាយស្រួល ដោយសារ តែអាស៊ាន ជាតំបន់ដែលមានចម្រុះភាសា មានចម្រុះជនជាតិ មានចម្រុះសាសនា មាន ចម្រុះនយោបាយ តាំងពីប្រជាធិបតេយ្យ រាជានិយមកុម្មុយនីស្ត រាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ រដ្ឋសហព័ន្ធ...។ល។

ជាចុងក្រោយសូមស្មារតីអាស៊ានរត់ ត្របាញ់បញ្ចូលគ្នាជាធ្លុងមួយ តាមទស្សនាទានសហគមន៍មួយ វាសនាតែមួយ ដើម្បី ឲ្យប្រជាជាតិទាំង១០ នៅក្នុងតំបន់រីក ចម្រើន ក្រោមយុទ្ធសាស្ត្រមួយ ដែលអាច នឹងឲ្យប្រជាជាតិទាំងអស់រួមគ្នាទទួលផល ប្រយោជន៍ស្មើៗគ្នា និងទាំងអស់គ្នា ដោយ ស្មើរមុខស្មើរមាត់ ៕

*ដោយ អរិយបុត្រ*



# ព្រះមហាក្សត្រ និងមហាក្សត្រិយ៍យាងសម្ពោធអគារពេទ្យតម្លៃ៨៧ម៉ឺនដុល្លារ

អគារមន្ទីរពេទ្យមួយខ្នងស្ថិតនៅក្នុងមន្ទីរពេទ្យសម្តេចឪសម្តេចម៉ែស្ថិតនៅសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ត្រូវបានព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានិងសម្តេចព្រះមហាក្សត្រី យាងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ កាលពីថ្ងៃទី៧ កុម្ភៈ ២០១៨។

អគារមន្ទីរពេទ្យនេះ គឺជាព្រះរាជអំណោយ ដ៏ថ្លៃថ្លាបំផុតរបស់សម្តេចព្រះមហាក្សត្រី មុនីនាថ ព្រះវររាជមាតាជាតិខ្មែរ។

លោក គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារទូទៅនៃក្រសួងព្រះបរមរាជវាំងឱ្យដឹងថា អគារនេះមានកម្ពស់ពីរជាន់ ដោយចំណាយថវិកាអស់ជាង៨៧ម៉ឺនដុល្លារអាមេរិកកសាងឡើងក្រោមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចព្រះមហាក្សត្រី តាមរចនាបថខ្មែរអាចផ្ទុកគ្រែអ្នកជំងឺបាន៤៣គ្រែ,បំពាក់ទៅដោយបរិក្ខាពេទ្យទំនើបៗជាពិសេសគួអគារទាំងមូលមានបំពាក់ទៅដោយប្រព័ន្ធការពារសុវត្ថិភាពនិងផ្លូវជម្រាលសម្រាប់ រុញគ្រែអ្នកជំងឺពេលកើតមានគ្រោះអគ្គិភ័យកន្លែងទទួល និងផ្តល់ព័ត៌មាន,បន្ទប់សង្គ្រោះបន្ទាន់,បន្ទប់វះកាត់, បន្ទប់សម្រាកក្រោយការវះកាត់, បន្ទប់វិទ្យុសាស្ត្រ, បន្ទប់អេកូសាស្ត្រ និងបន្ទប់ពិនិត្យផ្ទៃពោះជាដើមផងដែរ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាលលោក ម៉ម ប៊ុនហេង មានប្រសាសន៍ថា មន្ទីរពេទ្យបង្អែកនេះ ស្ថិតក្នុងការិយាល័យស្រុកប្រតិបត្តិមេគង្គនៃមន្ទីរសុខាភិបាល រាជធានីភ្នំពេញគ្របដណ្តប់លើប្រជាជនចំនួន២២ ម៉ឺននាក់ដែលរស់នៅក្នុងខណ្ឌឫស្សីកែវ និងខណ្ឌជ្រោយចង្វា។

មន្ទីរពេទ្យសម្តេចឪ សម្តេចម៉ែនេះត្រូវបានសាងសង់ឡើងក្រោមព្រះរាជតម្រិះរបស់សម្តេចឪក្នុងទសវត្សឆ្នាំ១៩៦០នៅពេលដែលព្រះអង្គដឹកនាំសម័យសង្គមរាស្ត្រនិយមដ៏រុងរឿងដែលអង្គសម្តេចឪ នៃយើងបានយកព្រះរាជហឫទ័យគិតគូរខ្ពស់បំផុតចំពោះវិស័យសុខាភិបាល៕

# រោងចក្រផលិតស៊ីម៉ង់ត៍តម្លៃ ២៦២ លានដុល្លារដំណើរការ

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចតេជោ ហ៊ុន សែន បានអញ្ជើញសម្ពោធដាក់ឲ្យដំណើរការរោងចក្រផលិតស៊ីម៉ងត៍របស់ក្រុមហ៊ុន ជីបម៉ុង អ៊ីនស៊ី ស៊ីមេន ឧបកើ-វេសិន ដែលមានតម្លៃ២៦២លានដុល្លារនៅស្រុកបន្ទាយមាសខេត្តកំពតនៅថ្ងៃទី៨ ខែកុម្ភៈនេះ។

រោងចក្រនេះវិនិយោគរួមគ្នារវាងក្រុមហ៊ុនជីបម៉ុងដែលមានភាគហ៊ុន៦០ ភាគរយ និងក្រុមហ៊ុនថៃស្យាមស៊ីធីស៊ីមែន។ នេះជារោងចក្រផលិតស៊ីម៉ង់ត៍ទី៤ របស់កម្ពុជាដែលរោងចក្រនេះមានសមត្ថភាពផលិតស៊ីម៉ង់ត៍បានក្នុងមួយថ្ងៃ ៥.០០០តោន ស្មើនិង ១,៧លានតោនក្នុងមួយឆ្នាំ និងផ្តល់ការងារអចិន្ត្រៃយ៍ដល់កម្មករប្រមាណជិត៨០០នាក់។

រោងចក្រផលិតស៊ីម៉ងត៍ ជីបម៉ុង អ៊ីនស៊ីស៊ីមេនថ្មីនេះមានទីតាំងស្ថិតនៅក្នុងភូមិព្រៃតាព្រិត ឃុំស្តេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត សាងសង់នៅលើផ្ទៃដីប្រមាណ ១១០ហិចតា។ លោក លាង ឃុន ម្ចាស់ភាគហ៊ុនធំនៃក្រុមហ៊ុន នេះបានថ្លែងថា វាគឺជារោងចក្រផលិតស៊ីម៉ង់ត៍ធំជាងគេមួយនៅក្នុងតំបន់ប្រកបដោយស្តង់ដារខ្ពស់ដោយមានបំពាក់ឧបករណ៍ និងគ្រឿងម៉ាស៊ីនទំនើបក្រោយបំផុតមកពីប្រទេសចិនអាល្លឺម៉ង់ ស៊ុយអែត និងអ៊ីតាលី ដែលធ្វើឱ្យការបញ្ចេញឧស្ម័នកាបូនកាបូនិចមានកម្រិតទាបបំផុត និងមានមាត្រដ្ឋានបរិស្ថានល្អកម្រិតអន្តរជាតិ។

លោក បន្តថាស៊ីម៉ង់ត៍ដែលផលិតចេញពីរោងចក្រនេះត្រូវបានចែកចេញ ជា៣ប្រភេទ គឺស៊ីម៉ង់ត៍អ៊ូដ្ឋពណ៌ទឹកក្រូច ស៊ីម៉ង់ត៍អ៊ូដ្ឋពណ៌បៃតង និងស៊ីម៉ង់ត៍ត្រៃយ៍ពេជ្រសម្រាប់ទីផ្សារអាជីវកម្ម។

សម្តេចតេជោហ៊ុនសែន បានសំដែងនូវការកោតសរសើរចំពោះក្រុមហ៊ុនដែលបានចាប់ដៃគូវិនិយោគរួមគ្នានៅតំបន់នេះ។ សម្តេចបានមានប្រសាសន៍ថា នេះជាឧស្សាហកម្មធុនធ្ងន់មួយ របស់កម្ពុជា បន្ទាប់ពីឧស្សាហកម្មធុនធ្ងន់មួយចំនួនដែលដំណើរការរួចរាល់ហើយនោះ។ សម្តេចថ្លែងថាយើងមិនមែនជាអ្នកមានមហិច្ឆិតានៅក្នុងឧស្សាហកម្មធុនធ្ងន់នេះទេប៉ុន្តែនេះជាតម្រូវការចាំបាច់ហើយវាក៏ជាលទ្ធភាពជាក់ស្តែងដែលកម្ពុជាអាចធ្វើទៅបាន។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានបន្តថាមកដល់ឆ្នាំ២០១៨ នេះកម្ពុជាមានលទ្ធភាពផលិត ស៊ីម៉ងត៍រហូតដល់ ៧ លានតោនក្នុង១ឆ្នាំ ដែលអាចបំពេញសេចក្តីត្រូវការប្រើប្រាស់នៅក្នុងប្រទេស និងការនាំចេញទៅក្រៅប្រទេស។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានបន្តថា តម្រូវការប្រើប្រាស់ស៊ីម៉ង់ត៍មិនមែនត្រឹមតែកម្ពុជាប៉ុណ្ណោះទេ គឺទូទាំងពិភពលោកតែម្តងនៅតែមានតម្រូវការចាំបាច់ហើយវានិងបន្តកើនឡើង ។

បើយោងតាមរបាយការណ៍របស់ក្រសួងរ៉ែ និងថាមពល ហូតមកដល់ពេលនេះវិនិយោគិនបានស្នើសុំនូវទីតាំងដីមានសក្តានុពលសម្រាប់ការវិនិយោគរោងចក្រស៊ីម៉ងត៍ចំនួន ៥ ក្រុមហ៊ុនរួចមកហើយ នៅខេត្តកំពតចំនួន៤ និងខេត្តបាត់ដំបងចំនួន ១។

បច្ចុប្បន្នក្រុមហ៊ុនស៊ីម៉ងត៍ពីរគឺក្រុមហ៊ុន K Cement ដែលបានវិនិយោគ ១៨០ លានដុល្លារ និងក្រុមហ៊ុនស៊ីម៉ង់កម្ពុជាចក្រីទីង ដែលបានវិនិយោគ ៩៩ លានដុល្លារកំពុងផ្គត់ផ្គង់ដល់ទីផ្សាររួចហើយខណៈក្រុមហ៊ុនស៊ីម៉ងត៍ថៃប៊ុនរ៉ុង ដែលវិនិយោគ ៤៥ លានដុល្លារកំពុងសាកល្បងចង្វាក់ផលិតកម្ម។

ក្រុមហ៊ុនស៊ីម៉ងត៍ជីប ម៉ុង និងក្រុមហ៊ុន ស៊ីម៉ងត៍ខ្យងបាត់ដំបងវិនិយោគ ៦០ លានដុល្លារគ្រោងនឹងដំណើរការនៅក្នុងឆ្នាំនេះ៕

# កម្ពុជា នឹងបន្តពង្រឹងនយោបាយចិនតែមួយ និងពូនជ្រុំទំនាក់ទំនងជាមួយនឹងចិនបន្ថែមទៀត

សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានរំលឹកឡើងវិញនាព្រឹកនេះអំពីទំនាក់ទំនងរវាងកម្ពុជានិងចិនដលែត្រូវបានផ្តួចផ្តើមដោយស្នាព្រះហស្តរបស់អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាសម្តេចព្រះនរោត្តមសីហនុដែលបានផ្តួចផ្តើមជាង ៦០ឆ្នាំមកនេះ។

ថ្លែងការនៅក្នុងពិធីបើកការដ្ឋានសម្រាប់ការសាងសង់ស្ពានមួយទៀតឆ្លងកាត់ទន្លេមេគង្គសម្តេចតេជោ ហ៊ុនសែនបានរំឭកឡើងវិញអំពីប្រវត្តិនៃទំនាក់ទំនងការទូតជាប្រវត្តិសាស្ត្ររវាងកម្ពុជា និងចិនដែលកសាងឡើងដោយ សម្តេចព្រះនរោត្តមសីហនុនិងលោកនាយករដ្ឋមន្ត្រីចិនទីមួយ ជូអេនឡាយ។

សម្តេចបានបញ្ជាក់ មនុស្សមួយចំនួនបានលើកឡើងនូវសំណួរមួយចំនួន (ហេតុអ្វីបានជាប្រទេសកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រទេសចិន) មូលហេតុនេះគឺថា ប្រទេសចិនតែងតែប្រកាន់ខ្ជាប់នូវគោលនយោបាយស្មើភាពនិងការគោរពគ្នា គ្នាទៅវិញទៅមក ដែលនេះគឺជានយោបាយពិសេសមួយនៅលើពិភពលោក។

សម្តេច តេជោហ៊ុនសែនក៏បានថ្លែងនូវ សុន្ទរកថាគួរឱ្យកត់សម្គាល់ដើម្បីអបអរសាទរ នូវការគាំទ្ររបស់រដ្ឋាភិបាល និងប្រជាជនចិន ចំពោះ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេសកម្ពុជា។

ស្ពានឆ្លងទន្លេមេគង្គស្ទឹងត្រង់-ក្រូចឆ្មារនេះ គឺជាស្ពានទី៨ហើយ ដែលសាងសង់ក្រោមហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលចិន។ ស្ពានចំនួន ៧ ដែលសាងសង់រួចរាល់កន្លងមករួមមាន ស្ពានមិត្តភាពកម្ពុជាចិនកោះធំ ស្ពានមិត្តភាពកម្ពុជាចិន ស្ពានជ្រោយចង្វា២ ស្ពានមិត្តភាពកម្ពុជាចិន សេកុងខេត្តស្ទឹងត្រែង ស្ពានមិត្តភាពកម្ពុជាចិន ព្រែកក្តាម ស្ពានមិត្តភាពកម្ពុជាចិន ព្រៃតាម៉ាក់ ស្ពានមិត្តភាពកម្ពុជាចិន មេគង្គស្ទឹងត្រែង និងស្ពានមិត្តភាពកម្ពុជាចិន តាខ្មៅ។

ក្រៅពីផ្តល់កម្ចីសាងសង់ស្ពានឆ្លងកាត់ទន្លេទៅ រដ្ឋាភិបាលចិន បានផ្តល់កម្ចីជួយសាងសង់ផ្លូវនៅកម្ពុជាបានប្រវែងជិត ២.០០០គីឡូម៉ែត្រ និង កំពុងសាងសង់ជិត ៧០០គីឡូម៉ែត្រ និងត្រៀមសាងសង់មួយចំនួនទៀត ។ កម្ចីដែលរដ្ឋាភិបាលចិនបានផ្តល់សម្រាប់សាងសង់ផ្លូវ និងស្ពាននៅកម្ពុជា មានទឹកប្រាក់ជាង ២.០០០លានដុល្លារអាមេរិក ៕

# ពលរដ្ឋយល់ខុសៗគ្នាអំពីកំណើនវត្តមានជន




សណ្ឋាគារ ភោជនីយដ្ឋាន កាស៊ីណូ ម៉ាស្សា សូម្បីតែហាងតូចតាចតាមដងផ្លូវនានានៅក្នុង ខេត្តព្រះសីហនុនាពេលនេះគឺមួយចំនួន ធំសុទ្ធតែត្រូវបានគេដឹងថា ត្រូវបានជួលផ្តាច់ទៅឲ្យ ភ្ញៀវទេសចរ ឬក៏ម្ចាស់អាជីវកម្មជនជាតិចិនទាំងអស់ៗតែម្តង។

លោក លី ហាក់សុន គឺជាប្រជាពលរដ្ឋម្នាក់ដែលមានទីលំនៅនាខេត្តព្រះសីហនុ បានមានប្រសាសន៍ថា បច្ចុប្បន្ននេះវត្តមានជនជាតិចិនកើនឡើងមែនទែន មិនថាតែនៅសណ្ឋាគារ ផ្ទះសំណាក់ទេ សូម្បីតែផ្ទះជួលដាក់ខែល្អមៗក៏ត្រូវបានចិនមកជួលយកទាំងមូលៗតែម្តង ហើយហ៊ានឲ្យថ្លៃខ្ពស់កប់ពពកទៀតផង។

លោកបានបញ្ជាក់ថា " ផ្ទះស្នាក់នៅជួលដាក់ខែធម្មតាតម្លៃមួយបន្ទប់ត្រឹម ៦០ ដុល្លារទៅ ៨០ ដុល្លារ ពីមុន មានត្រឹម ១០ ទៅ ២០បន្ទប់ អ៊ីចិនហ៊ានជួលផ្តាច់ ពី ២.០០០ ដុល្លារ ទៅ ៤.០០០ ឬ៥.០០០ ដុល្លារក៏មានដែរ "។

លោកបានបន្តទៀតថា ជនជាតិចិនគេអត់សាញច្រើនទេ ត្រឹមតែមកមើលទីតាំង និយាយថ្លៃជួលតែម្តង ហើយអ្នកមានដីមានផ្ទះធំៗ ឥឡូវធូរធារច្រើនណាស់ដោយសារតែវត្តមាន ចិន។

ម្ចាស់ផ្ទះជួលមួយរូបនៅខេត្តព្រះសីហនុ ដែលបានអះអាងប្រាប់ត្រឹមឈ្មោះថា ស៊ុន ហុង អាយុ ៥៩ឆ្នាំ ដែលសព្វថ្ងៃលោកមានផ្ទះជួលមួយកន្លែងដែលមានប្រមាណជា ៣០បន្ទប់ និងមាន ហាងលក់ដូរបន្តិចបន្តួចទៀត បានឲ្យដឹងថា ចិនគេមកទាក់ទងលោកជួលផងដែរ ប៉ុន្តែលោកមិនជួលឲ្យទេស្តាយផ្ទះព្រោះខំធ្វើខំកសាងឡើង ហើយលោកសុខចិត្តគ្រប់គ្រងសុខចិត្តទុកលំបាកខ្លួនឯង ដោយសារតែគេល្បីថាជនជាតិចិនមិនសូវថែផ្ទះសម្បែងទេ តែជួលឲ្យគេបានលុយច្រើនមែន តែផ្ទះហ្នឹងខ្ទេចតែម្តងពេលចប់កុងត្រា។

លោកបានបញ្ជាក់ថា "ផ្ទះខ្ញុំនេះ ពួកចិនគេចង់មកជួលដែរ ដោយឲ្យមួយខែគេហ៊ានឲ្យដល់ទៅ ៨.០០០ដុល្លារ ឯណោះ ប៉ុន្តែខ្ញុំអត់ជួល សុខចិត្តជួលឲ្យខ្មែរ ឲ្យហ្វីលីពីន ឲ្យបរទេសមួយចំនួនដែលមកធ្វើការនៅទីនេះ បានមួយខែ មួយបន្ទប់ ១៥០ ដុល្លារវិញ"។

លោកបានបន្តទៀតថា ផ្ទះ ដី ផ្ទះសំណាក់នៅជិតៗលោក គេជួលយកលុយដុំៗ អស់ហើយ ដោយគេនិយាយថា ខ្ទេចក៏ខ្ទេចទៅ ពីព្រោះគេឲ្យដល់ថ្លៃហើយ។ លោកបានបន្តទៀតថា ការជួលរបស់ជនជាតិចិនទៀតសោត គឺក្រៅពីឲ្យថ្លៃហើយនោះ ថ្លៃកក់ក៏យូរដែរគឺសុទ្ធតែកក់លុយ ១ឆ្នាំមុនក៏មានដែរ ។

លោកបានបន្តទៀតថា ពេលខ្លះលោកក៏ចង់ជួលយកលុយដុំនឹងគេដែរ តែចេះតែមានមនោសញ្ចេតនា ជាមួយនឹងអ្នកជួលដែលគ្មានករស់នៅជាមួយលោក កវែកកឆ្នាំងជាមួយគ្នា តាំងពីមួយបន្ទប់ថ្លៃ ៧០ ដុល្លារ ទៅ ៨០ដុល្លារអី ឥឡូវគេហ៊ានឡើងរហូតដល់ ១៥០ដុល្លារ នៅក្នុងមួយខែ ហើយបន្ទប់ដែលរាងធំទូលាយបន្តិចទៅ ២០០ដុល្លារហើយដែរ។ បើយើងលែងជួលឲ្យគេ ពួកគេអាចលំបាករកកន្លែងស្នាក់នៅសមរម្យ ជិតកន្លែងធ្វើការបន្តទៀត ហើយម្យ៉ាងទៀត កូនៗរបស់ លោកក៏មានមុខរបរលក់នេះលក់នោះ គ្រាន់តែចិញ្ចឹមជីវិត។

លោកបានបញ្ជាក់ថា "ទុកទៅ (មិនជួលឲ្យចិន) គ្រាន់នឹងឲ្យកូនវារៀនរកស៊ីរៀនខាតរៀនចំណេញ បើជួលឲ្យចិនដល់ខែ យកលុយៗ ចេះស៊ីតែចិនចេញអស់ ដឹងតែងាប់ហ្មង ចឹងហើយបានជាមិនជួលឲ្យគេ ទុកគ្រាន់ឲ្យពួកគេរៀនរករៀនខាតនឹងគេ"។

លោក ហ៊ីង ចម្រើន ជាអ្នករត់ឡានកាត់ដំបូលតែហៅថា ទុកៗដែរនោះបានឲ្យដឹងថា "ម៉ាឆ្នាំនេះ ចិនមកច្រើនណាស់ ពួកគេសម្រុកមកខេត្តព្រះសីហនុហ្មង"។

លោកបានបន្តថា បើឡានក្រុងមកពីភ្នំពេញ និងមកពីសៀមរាប គឺចម្រុះ មានខ្មែរមាន បរទេសមកពីលោកខាងលិច មានជនជាតិចិនខ្លះដែរ ប៉ុន្តែប្រសិនជាឡានក្រុងនោះមកពីព្រលានវិញគឺដឹងតែពេញៗសុទ្ធតែចិនតែម្តង។

លោកបានបន្តទៀតថា ពេលខ្លះលោកអាណិតអ្នកទេសចរជនជាតិខ្មែរយើងតែម្តង អាណិតត្រង់ គាត់ជិះទៅរកអូតែលស្នាក់នៅមិនបាន ដោយសណ្ឋាគារមួយៗគឺពេញសុទ្ធតែចិនតែម្តង។

លោកបានបញ្ជាក់ថា "មិនអាណិតម៉េច បើគាត់ជិះតុកតុកខ្ញុំ ចេញពីសណ្ឋាគារមួយទៅមួយធ្លាក់ដល់ផ្ទះសំណាក់ខ្លះ ហើយនៅរកកន្លែងដេកចង់មិនបាន ហើយថ្លៃទៀត"។

លោកបានបន្តទៀតថា ភ្ញៀវបរទេសមកពីអឺរ៉ុបអី គេសុទ្ធតែកក់មុន ដូច្នេះមិនជាអីទេ គេដឹងតែមានកន្លែងហើយ ទោះថ្លៃ ទោះថោក ដឹងតែមាន ប៉ុន្តែខ្មែរយើងដែលមិនទម្លាប់អារឿងកក់ ហើយអាងថា សណ្ឋាគារនិងផ្ទះសំណាក់វាមិនខ្វះមិនកក់ពេលមកលេងម្តងៗ មានអីចង់ងាប់ ហើយដើរឡើងក្រហមមុខដែរហ្នឹង ប៉ះពេលថ្ងៃត្រង់អីនោះ ។

ទាក់ទិននឹងស្ថានភាពបែបនេះ លោក ដេត ណារិន ដែលបានបើកឡាននាំគ្រួសារមក លេងកំសាន្តនៅចុងសប្តាហ៍នៅខេត្តព្រះសីហនុថ្មីៗនេះ បាននិយាយទាំងខកចិត្តផង សើចផងថា ពិបាករកកន្លែងស្នាក់នៅមែនខេត្តព្រះសីហនុឥឡូវនេះ។ លោកបានអះអាងថា នៅពេលដែលលោករៀបចេញមកមិត្តភក្តិគេប្រាប់ដែរថា គួរតែកក់អូតែល

# ជាតិចិនមកខេត្តព្រះសីហនុ




ថតដោយ អរិយបុត្រ

ឲ្យហើយដែរ ប៉ុន្តែដោយរវល់ ហើយចេះតែភ្លេច ម៉្យាងវិញទៀតគិតថា គេងត្រឹមតែ១យប់២អី ចាំបាច់កក់ធ្វើអី ខ្ជះអីសណ្ឋាគារ និងផ្ទះសំណាក់នោះ។

លោកបានបញ្ជាក់ថា "ខ្ញុំបើកឡានដើររកបួនសណ្ឋាគារហើយ សុទ្ធតែពេញដល់ថ្នាក់សុខា ផ្កាយប្រាំ ដែលថ្លៃ ហើយមិនដែលពេញនោះ ក៏ពេញដែរ"។

លោកបានបញ្ជាក់ទៀតថា "ខេត្តព្រះសីហនុឥឡូវនេះ មិនជឿមិនបានមែន !"។

លោកស្រី ណុប អ្នកលក់មឹកអាំង នៅតាមឆ្នេរបានឲ្យដឹងថា ឥឡូវដូចជាស្ងាត់ហើយបេរ លោកស្រីក៏មិនសូវជាដាច់ដែរ ខណៈដែលទីកន្លែងស្នាក់នៅក៏កាន់តែឆ្ងាយ។ លោកស្រី បានឲ្យដឹងថា ឥឡូវនេះភ្ញៀវទេសចរខ្មែរមិនសូវមកលេងនៅកំពង់សោមទេ (ខេត្តព្រះសីហនុ) អ្នកដែលមកក៏កម្រមកលេងនៅឆ្នេរដែរ ដោយសារតែឥឡូវមិនសូវមានឆ្នេរសាធារណៈទៀតទេ។ ហើយអ្នកខ្លះ ដែលមកកំពង់សោម គឺនិយមទៅលេងនៅកោះប៉ុណ្ណោះ។

លោកស្រី ណុប បានបញ្ជាក់ថា "តាំងពីចិនមកច្រើន ភ្ញៀវខ្មែរដូចជាស្ងាត់ហើយ តែភ្ញៀវខ្មែរស្ងាត់បេរខ្ញុំក៏ចប់ដែរ។ មានចិន មានអឺរ៉ុបណាទៅស៊ី មឹកអាំង គឺមានតែខ្មែរយើងហ្នឹង ដែលនិយមចូលចិត្ត"។

លោកស្រីបានបន្តទៀតថា ក្រៅពីពិបាកលក់ដូរហើយនោះ លោកស្រីក៏ពិបាកនៅក្នុងការ ធ្វើដំណើរថែមទៀត ដោយសារតែឥឡូវនេះ ត្រូវរើទៅនៅ ឆ្ងាយ ដោយសារតែ នៅម្តុំផ្សារលើ ដែលលោកស្រី ធ្លាប់ជួលគេស្នាក់នៅទីនោះ ម្ចាស់គេរើឈប់ជួល ហើយជួលឲ្យចិន អស់ហើយ។

លោកស្រីបានបន្តទៀតថា "កាលជួលនៅផ្សារលើខ្ញុំអាចដើរលេងៗ លក់បណ្តើរដើរបណ្តើរដល់កន្លែងស្នាក់នៅហើយ តែពេលនេះ ទាល់តែជិះម៉ូតូឌុប ឬតុកតុកបានទៅដល់ វាឆ្ងាយ "។

កញ្ញា សុភាព ដែលជាអ្នកជួយគេលក់ដូរ និងជួលទីកន្លែងនៅម្តុំ ឆ្នេរអូរឈើទាលបានឲ្យដឹងថា ភ្ញៀវខ្មែរឥឡូវនេះស្ងាត់ច្រើន ហើយ ភ្ញៀវអឺរ៉ុប ក៏ស្ងាត់ដែរ។

កញ្ញា បានបញ្ជាក់ថា "រាល់ដង ឲ្យតែថ្ងៃសៅរ៍ អាទិត្យ គឺមនុស្សមកលេងពេញៗ រវល់រកពេលទំនេរគ្មាន នៅតាមតូបនីមួយៗ តែពេលនេះ ភ្ញៀវមកមួយៗ ហើយបើអឺរ៉ុបវិញ គឺដឹងតែទៅកោះអស់ហើយ"។

លោកហេង ចំណូល ប្រជាពលរដ្ឋដែលរស់នៅទីក្រុងភ្នំពេញមួយរូប បានឲ្យដឹងថា លោក ធ្លាប់ឃើញទិដ្ឋភាពនៅខេត្តព្រះសីហនុ ហើយ ដូច្នេះបើសិនជាលោកចង់នាំគ្រួសារទៅលេងនៅសមុទ្រ គឺប្រហែលជាមិនទៅទីនោះទៀតទេ ប៉ុន្តែអាចទៅ កំពត ឬកែប ព្រោះល្បីថា ទីនោះឥឡូវមានឆ្នេរស្អាតៗច្រើន ហើយមិនសូវមានចិន ។

លោកបានបន្តទៀតថា តាមដែលលោកធ្លាប់បានទៅធ្វើការ ឃើញសុទ្ធតែចិន ប៉ុន្តែដូចជាមិនមែនទៅលេងសមុទ្រអីទេ គឺភាគច្រើនទៅកាស៊ីណូតែម្តង ពីព្រោះកន្លែងណាក៏មានកាស៊ីណូដែរ៕

ដោយ អរិយបុត្រ

## ភ្ញៀវទេសចរចិនមកកម្ពុជាកើនឡើង៤៦ ភាគរយ

ក្រសួងទេសចរណ៍បានអះអាងថា កាលពីឆ្នាំ ២០១៧កន្លងទៅនេះ កម្ពុជា ទទួលបានទេសចរ អន្តរជាតិចំនួន ៥,៦ លាននាក់ កើនឡើង ១១,៦% ក្នុងនោះភ្ញៀវទេសចរជនជាតិចិនស្ថិតលំដាប់ទី១។

ក្រសួងទេសចរណ៍បានបង្ហាញនូវស្ថិតិថា ភ្ញៀវទេសចរជនជាតិចិន កាលពីឆ្នាំទៅបានរុញច្រានភ្ញៀវទេសចរវៀតណាមទៅលំដាប់ទី២ ។

ប្រភពដដែលបានបន្តថា ភ្ញៀវទេសចរជនជាតិចិន ដែលបានមកលេងនៅកម្ពុជានៅឆ្នាំ២០១៧ គឺមានសរុបជាង ១,២ លាននាក់ ពោលគឺមានការកើនឡើង ៤៦%។

ជាមួយនឹងកំណើននេះ ប្រភពដដែលបានបញ្ជាក់ថា បច្ចុប្បន្ន មានក្រុមហ៊ុ ន អាកាសចរណ៍ចំនួន ១៥ ក្រុមហ៊ុន ដែលបានបើកចំហរជើងហោះហើរកម្ពុជានិងចិន ដោយកម្ពុជាមានក្រុមហ៊ុនចំនួន ០៣ ហើយចិនមាន ១២ ក្រុមហ៊ុន។

ប្រភពដដែលបានបន្តថា ក្រុមហ៊ុនទាំងនោះបានធ្វើប្រតិបត្តិការហោះហើរទៀងទាត់ ដើម្បីភ្ជាប់រវាងកម្ពុជានិងចិន មានចំនួន ១៥៥ ជើង ក្នុងមួយសប្តាហ៍ និងជើងហោះហើរពិសេស (Charter Flight) ដែលមានប្រមាណ ៥០ ជើងទៀត ក្នុងមួយសប្តាហ៍។

តាមការ ព្យាករណ៍នៅឆ្នាំ ២០២០ កម្ពុជារំពឹងថា នឹងអាចទាក់ទាញភ្ញៀវទេសចរអន្តរជាតិរហូត ដល់ប្រមាណ ៧លាននាក់ ក្នុងនោះទេសចរចិនយ៉ាងតិច ២លាននាក់ ដោយនាំមកនូវចំណូល ដែលគេរំពឹងថា នឹងទទួលបានសរុបប្រមាណ ៥០០០ លានដុល្លារ និងបង្កើតឱកាសការងារដោយផ្ទាល់ប្រមាណជិត ១ លាននាក់ ៕

## ខេត្តព្រះសីហនុមានគម្រោងសាងសង់អគារខ្ពស់ៗប្រមាណ ២០ គម្រោង

នៅខេត្តព្រះសីហនុមានគម្រោងសាងសង់ជាអគារខ្ពស់ៗប្រមាណជា ២០ គម្រោងនៅតាមទីតាំង សំខាន់នានា នៅក្នុងខេត្ត ។ នេះបើតាមការអះអាងរបស់មន្ត្រីជាន់ខ្ពស់នៅសភាពាណិជ្ជកម្មខេត្ត ព្រះសីហនុមួយរូប ។

ប្រភពដដែលបានបន្តថា សំណង់អាគារខ្ពស់ៗទាំងនេះ គឺទាំងអស់កសាងនិងវិនិយោគដោយក្រុម ហ៊ុនចិន ផ្សេងៗ ហើយភាគច្រើនគឺចាប់ផ្តើមកាលពីឆ្នាំ២០១៧កន្លងទៅ ដោយនៅក្នុងនោះ គម្រោងខ្លះគឺអាចនឹងសាងសង់រួចរាល់នៅឆ្នាំ២០១៨នេះ។

លោកបានបញ្ជាក់ថា "ចិនសាងសង់លឿនណាស់ គ្រាន់តែបុកគ្រឹះ ភ្លេចត្រចៀកគឺឡើងជិតដល់ពពក"។

ប្រភពដដែលបានបន្តថា តាមព័ត៌មានដែលដឹងគឺថា សំណង់អាគារខ្ពស់ៗទាំងនេះ គឺជារីសត សណ្ឋាគារ និង កាស៊ីណូ ហើយក៏មាន ជាខុនដូ ខ្លះៗផងដែរ ។

ប្រភពដដែលបានបន្តទៀតថា កាលពីឆ្នាំទៅ ចិនដាក់ទុនមកព្រឹបៗ យកតែម្តងហើយមិនសូវ ចេះ សូញសាញច្រើនទេ គឺបុកគ្រឹះសាងសង់យកតែម្តង៕

# អាជីវកម្មកាហ្វេកំពុងតែមានការកើនឡើង ចំណូលក៏ប្រសើរ

បច្ចុប្បន្ននេះការនិយមកាហ្វេ កំពុងតែមានកំណើនកើនឡើងនៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា មិនថាបុរសឬស្ត្រីក្មេងឬចាស់ ដោយពួកគេខ្លះអាចទទួលទានកាហ្វេ យ៉ាងតិច២កែវក្នុងមួយថ្ងៃ ដែលជាហេតុធ្វើឲ្យការប្រកបរបរលក់កាហ្វេ សឹងតែមានគ្រប់ផ្លូវនៅក្នុងប្រទេសជាពិសេសនៅតាមទីប្រជុំជននានា។

កាហ្វេទាំងនេះមានទាំងលក់ក្នុងហាងទំនើប និងការដាក់តាំងលក់នៅតាមចិញ្ចើមផ្លូវ តាមរទេះ និងការចល័តយន្តកែច្នៃរបស់អ្នកប្រកបរបរលក់កាហ្វេ ដែលទាំងនេះហាក់មានការចាប់អារម្មណ៍ពីសំណាក់ប្រជាពលរដ្ឋ។

យើងឃើញថា នាពេលបច្ចុប្បន្ននេះ កាហ្វេជាភេសជ្ជៈម្យ៉ាង ដែលប្រជាពលរដ្ឋនិយម ជាពិសេសយុវវ័យ ដែលក្នុងនោះមិនថាទាំងរាជធានីភ្នំពេញ ក៏ដូចជាបណ្តាខេត្តនានានោះទេ សម្រាប់ហាងកាហ្វេមានការបើកលក់ជាបន្តបន្ទាប់ ដែលមានទាំងកាហ្វេនាំចូល និងកាហ្វេលក់នៅតាមដងផ្លូវនៅតាមទីតាំងផ្សេងៗគ្នា ដែលក្នុងនោះទាំងរសជាតិ គុណភាព ក៏ដូចជាតម្លៃអាចទទួលយកបាន។

លោកស្រី កឹម ហ៊ន ជាម្ចាស់ហាងកាហ្វេដែលមានឈ្មោះថា បៃខូហ្វី (Bike Coffee) បានថ្លែងថា មូលហេតុដែលជំរុញឲ្យគាត់បង្កើតហាងកាហ្វេខ្លួនឯងនេះ ដោយសារតែបច្ចុប្បន្ននេះការទទួលទាន កាហ្វេប្រើនៗ ហើយរួចទៅនាងលោកស្រីនឹកឃើញថា តាមដងផ្លូវមិនទាន់មាននរណាម្នាក់សូវចាប់អារម្មណ៍បង្កើត ដែលលោកស្រីនឹកឃើញក៏បង្កើតខ្លួនឯង។ តូបមួយនេះចំណាយអស់ប្រហែលជា ២.០០០ ទៅ២.០០០ ដុល្លារបន្តិចបន្តួច ដែលយើងអាចបង្កើតបានក្នុងនោះឧបករណ៍ ប្រើប្រាស់មានដូចជាម៉ាស៊ីន កាហ្វេ និងម៉ាស៊ីនកិនជាដើម ព្រមទាំងរបស់ដែលផ្សំរផ្សេងៗ។

លោកស្រី កឹម ហ៊ន បានបន្តថា សម្រាប់វិធីធ្វើកាហ្វេនេះ លោកស្រីបានទៅសិក្សានៅសាលា ហើយបច្ចុប្បន្ន ក្នុងមួយថ្ងៃលោកស្រី អាចលក់ដាច់អស់ ប្រហែល ៧០កែវ ។

លោកស្រីបញ្ជាក់ថា "ឥលូវលក់ដាច់គ្រាន់បើ ភាគច្រើនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ចំណែកសៅអាទិត្យ អ្នកធ្វើការគាត់សម្រាក សិស្សក៏ឈប់សម្រាក ដែលកាហ្វេខ្ញុំនេះមានច្រើន ចំពោះពួក ផ្ទប្រចឹងខ្ញុំលក់ ៧០០០៛ ឡាតេ កាហ្វេដោះគោ ខ្ញុំលក់បាន ៥០០០រៀល"។

លោកស្រី កឹម ហ៊ន បានបន្តទៀតថា អាជីវកម្មលក់កាហ្វេលោកស្រី គឺប្រសើរទោះបីជាមានហាងកាហ្វេច្រើន តែលោកស្រីនៅតែទទួលបានអតិថិជនជាប្រចាំ។

លោកស្រីបានបញ្ជាក់ថា "លក់ទីតាំងកន្លែងនេះ គឺអតិថិជនគាត់ មើលឃើញកន្លែងខ្ញុំនេះអនាម័យ ហើយណាមួយគាត់មកទិញគាត់មិនព្រួយបារម្មណ៍ដូចថា មានបញ្ហាអ្វីកើតឡើង ចំពោះសុខភាព ដែលមុខរបរនេះអាចផ្គត់ផ្គង់គ្រួសារខ្ញុំបាន"។

ចំណែកអ្នកដែលនិយមគាំទ្រកាហ្វេដែលធ្វើការដាក់តាំងលក់នៅតាមដងផ្លូវក៏បានបង្ហាញអំពីអារម្មណ៍ក្នុងការគាំទ្រផលិតផល កាហ្វេដែលកំពុងតែមានប្រជាប្រិយភាពទាំងនេះផងដែរ។

កញ្ញា ជាតិ ជាយុវនារីមួយរូប បានថ្លែងថា ភាគច្រើនកញ្ញា មកញ៉ាំកន្លែងលក់កាហ្វេ លោកស្រី កឹម ហ៊ន នេះព្រោះថារសជាតិ ឆ្ងាញ់ហើយសេវាកម្មទាន់ចិត្ត។

កញ្ញា បានបញ្ជាក់ថា "មុនដំបូងនាងខ្ញុំគិតថានៅតាមចិញ្ចើមផ្លូវ តែពេលខ្ញុំញ៉ាំរសជាតិទៅ គឺប្រហាក់ប្រហែលនឹងការលក់នៅក្នុងហាងធំៗដែរ ហើយសម្រាប់ពេលវេលាដែលខ្ញុំមកទិញគាត់គឺមានភាពរហ័ស វាងាយស្រួលចំណេញពេលវេលាជាង នៅក្នុងហាងទាំងថវិការ និងពេលវេលា"។

កញ្ញា ជាតិ បានបន្តថា ការទិញកាហ្វេនៅតាមផ្លូវនេះ វាលឿនហើយមិនសូវចំណាយពេលវេលាយូរ ជាងការវេចខ្ចប់នៅក្នុងហាង ដោយសារតែខ្ញុំអ្នកធ្វើការចឹង ខ្ញុំចង់បានពេលវេលាលឿនចឹង។ ខ្ញុំយល់ថាល្អព្រោះថាខ្ញុំមើលទៅតាមប្រទេសជាច្រើន គេជឿនលឿនក្នុងការបើកលក់របៀបនេះ ខ្ញុំចង់និយាយថាប្រសិនបើប្រជាជនខ្មែរ គាត់បើកលក់ចឹង ប្រជាជនយើងវិវត្តន៍រីកចម្រើនដូចបណ្តាប្រទេសគេដែរ។

កញ្ញា លក្ខិណា ជាអ្នកនិយមកាហ្វេមួយរូបទៀតបានថ្លែងថា មូលហេតុដែលកញ្ញាមកទិញកាហ្វេនៅទីតាំងតាមដងផ្លូវដូចនេះ ដោយសារតែមានរសជាតិឆ្ងាញ់ អនាម័យ គុណភាព សោភណ្ឌភាពល្អ អាចទទួលយកបាន ទាំងសេវាកម្ម និងការរាក់ទាក់ មិនចាញ់ការទទួលទាននៅតាមបណ្តាហាងធំៗនោះទេ។ កាហ្វេនៅតាមដងផ្លូវ និងកាហ្វេដែលដាក់លក់នៅតាមហាងប្រ៊ែនៗ វាមិនមានការចាញ់គ្នាប៉ុន្មាននោះទេ។

គួរបញ្ជាក់ថា ប្រទេសកម្ពុជាមិនត្រឹមតែមាន ហាងកាហ្វេនៅតាមដងផ្លូវតែមួយមុខប៉ុណ្ណោះទេ ក៏នៅមានហាងកាហ្វេម៉ាកល្បីៗជាច្រើនទៀត ដែលក្នុងនោះរួមមាន អាម៉ាសូន ស្តាបាក ជាដើមដែលសុទ្ធសឹងតែជាម៉ាកកាហ្វេល្បីៗ នាំចូលពីបរទេស ៕

*ដោយ សុផានិត*



ថតដោយៈ វិទ្ធី

# ពិធីបញ្ចុះបឋមសិលា អគារសិក្សាបឋមសិក្សាសិល្បៈសន្ត ហ្វ្រង់ស្វ័រ

អគារនៃសាលាបឋមសិក្សាចំណេះទូទៅ និងសិល្បៈ សន្ត ហ្វ្រង់ស្វ័រ នៅភូមិចំការទៀង ស្រុកត្រាំកក់ ខេត្តតាកែវ បានបាព្វពិធីបញ្ចុះបឋមសិលា កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៨កន្លងទៅនេះ ក្រោមអធិបតីភាព របស់លោក អូលីវីយេ ឈ្មឺតហាស្លែរ អភិបាលព្រះសហគមន៍កាតូ-លិកភូមិភាគភ្នំពេញ និងជាស្ថាបនិកនៃសាលាបឋមសិក្សាមួយនេះ និងលោកស្រីប៉េហ្គី ម្ចាស់ជំនួយក្នុងការសាងសង់អគារនេះ។ ពេលចាប់ផ្តើមដែលជាកិច្ចស្វាគមន៍ មានរបាំជូនពរ ដែលសម្តែងដោយកុមារី សិស្សថ្នាក់ទី១ នៃសាលាបឋមសិក្សាសន្ត ហ្វ្រង់ស្វ័រ។ កុមារទាំងអស់នោះបានបញ្ចេញទេពកោសល្យយ៉ាងល្អ។

តាមរបាយការណ៍របស់លោកស្រីទ្វៃ មករា អ្នកសម្របសម្រួលការិយាល័យអប់រំសិក្សា នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានឲ្យដឹងថា ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ មានចំនួន ៣៥នាក់ ស្រីចំនួន១៩នាក់។ លោកស្រីបានបន្តថា កម្មវិធីសិក្សាគឺស្របតាមគរុកោសល្យ និងកម្មវិធីរបស់ក្រសួងអប់រំ ហើយមានបន្ថែមមុខវិជ្ជា កុំព្យូទ័រ ភាសាអង់គ្លេស កសិកម្ម និងសិល្បៈ និងតន្ត្រី។ ម៉ោងសិក្សាពីម៉ោង ៧ ដល់ម៉ោង ៤រសៀល។ អាហារថ្ងៃត្រង់សាលាផ្តល់ឲ្យសិស្សទទួលទាននៅសាលា ដោយមិនគិតថ្លៃ ។

លោក អ៊ុំ សាមាន នាយកការិយាល័យសិល្បៈភូមិភាគភ្នំពេញ និងជានាយកផ្នែកសិល្បៈបានឲ្យដឹងថា សិល្បៈគឺបង្រៀនមូលដ្ឋានគ្រឹះសិល្បៈ និងអក្សរភ្លេង ពីថ្នាក់ទី១-៣ ហើយថ្នាក់ទី៤-៦ សិស្សអាចរើស តាមឧបករណ៍ភ្លេងដែលគេចូលចិត្ត។ ចំពោះសិល្បៈ អាចបន្ថែមរបាំផ្សេងៗ និងល្ខោននានាផងដែរ។

កម្មវិធីសិក្សានឹងបញ្ចូលមុខវិជ្ជាកសិកម្មលើមូលដ្ឋានគ្រឹះកសិកម្ម។ ក្នុងពិធីនេះដែរលោកស្រីប៉េហ្គី ម្ចាស់ជំនួយក្នុងការសាងសង់អគារសិក្សានេះ បានមានប្រសាសន៍ថា អរគុណដែលបានរៀបចំពិធីនេះហើយលោកស្រីជូនពរឲ្យកុមារទាំងអស់ដែលនិងសិក្សានៅទីនេះឲ្យបានទទួលផលប្រយោជន៍ពីសាលានេះ។ សូមព្រះជាម្ចាស់ប្រទានពរដល់គ្រប់គ្នា។ ក្នុងឱកាសនេះដែរលោកអភិបាល បានមានប្រសាសន៍ថា ថ្ងៃនេះពិតជាមានអំណរសប្បាយ ដែលយើងចាប់ផ្តើមសាលាបឋមសិក្សាសិល្បៈ។ លោកអភិបាលបន្តថា នៅកម្ពុជាមិនមានសាលាបឋមសិក្សាសិល្បៈបែបនេះច្រើនទេ។ យើងត្រូវជួយឲ្យកូនៗមានការរីកចម្រើននូវទេពកោសល្យដែលគេមាន។ ពួកគេមានទេពកោសល្យណាស់ ហើយពួកគេមានមូលដ្ឋានតាំងពីពួកគេរៀននៅសាលាមត្តេយ្យម៉ុងតេសូរីរបស់យើង ។លោកក៏បានរំលឹកអំពីភាពសំបូរបែបនៃរបាំ និងសិល្បៈរបស់កម្ពុជាតាំងពីបូរាណមក។ ប៉ុន្តែបានបាត់បង់ស្ទើសូន្យក្នុងរបបប៉ុលពត។ ក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះបានរស់ឡើងវិញ។ ដូច្នេះយើងត្រូវរួមគ្នាថែរក្សា វប្បធម៌របស់យើងដែលជាបេតិកភណ្ឌពិភពលោកឲ្យបានគង់វង្ស។

លោកបញ្ជាក់ថាសាលាបឋមសិក្សានេះជាសាលាទំនើបនៅកម្ពុជាដែលព្រះសហ-គមន៍កាតូលិកភូមិភាគភ្នំពេញ បានបង្កើតឡើងចាប់ពីសាលាមត្តេយ្យ តាំងពីឆ្នាំ ២០០២ រហូតមកដល់ពេលនេះ មានរួមទាំងពីសាលាមត្តេយ្យ បឋមសិក្សា អនុ-វិទ្យាល័យ វិទ្យាល័យ វិទ្យាល័យបច្ចេកទេស និងវិទ្យាស្ថានជាដើម៕




ថតដោយ សុធីរិទ្ធ

# ក្រុមការងារនៃក្រសួងបរិស្ថានចុះពិនិត្យលើព្រំដី ដែលនឹងត្រូវប្រគល់ជូនដល់ព្រះសហគមន៍កាតូលិកនៅបូកគោ

ក្រុមការងារ នៃក្រសួងបរិស្ថាន និងព្រះសហគមន៍សហគមន៍ បានចុះទៅដល់ទីតាំងបរិវេណព្រះវិហារកាតូលិកដ៏ចំណាស់នៅលើកំពូលភ្នំបូកគោ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៨ដើម្បីពិនិត្យឡើងវិញនូវព្រំដីបរិវេណព្រះវិហារ ដែលបានចុះវាស់វែងនាពេលកន្លងទៅ។

ក្រុងការងារនេះ ដឹកនាំដោយ លោក សូឃុន ឫទ្ធិគុណ អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ដោយមានការចូលរួម ពីសំណាក់ ប្រធានមន្ទីរបរិស្ថានខេត្តកំពត ប្រធានមន្ទីរ ធម្មការ និងសាសនាខេត្តកំពត លោកបូជាចារ្យ យ៉ាំងលូកា បូជាចារ្យទទួលខុស ត្រូវមណ្ឌល សកម្មភាពព្រះ-សហគមន៍កាតូលិក ខេត្តកំពត និងលោក គឹម រតនា ប្រធានអង្គការការីតាសកម្ពុជា។

ក្រុមការងារបាន ពិនិត្យមើល ព្រំដីទាំងប៉ុន្មាន ដែលបានវាស់រួចហើយដោយមន្ត្រីនៃមន្ទីរបរិស្ថានខេត្តកំពត និងក្រុមការងារព្រះសហគមន៍កាតូលិក នាពេលកន្លងមក។ ដីដែលបានវាស់ហើយមានពី ជម្រើស គឺ ជម្រើសទីមួយមានទំហំ ២,៧ ហិតា និងជម្រើសទី២ មានទំហំ ៤,៨ ហិតា។



ថតដោយ លី សុវណ្ណា

ក្រោយពិនិត្យរួចរាល់លើព្រំដីដែលបានវាស់ហើយ លោកសូឃុន ឫទ្ធិគុណ អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន បានផ្តល់យោបល់ដល់ក្រុមការងារនៃមន្ទីរបរិស្ថាន និងតំណាង ព្រះសហគមន៍កាតូលិក ឲ្យពិនិត្យឡើងវិញនូវព្រំដែលបានកំណត់រួចហើយ និងស្នើឲ្យព្រះសហគនន៍កាតូលិករៀបចំប្លង់មេនៅលើដី ដែលនឹងទទួលនោះឲ្យបានឆាប់រហ័ស ដើម្បីដាក់ជូនដល់រដ្ឋមន្ត្រី ធ្វើការសម្រេច និងប្រគល់ជូនព្រះសហគមន៍កាតូលិកវិញបានឆាប់រហ័ស។

លោកក៏បានស្នើដែរថា នៅក្នុងប្លង់មេធ្វើយ៉ាងណាត្រូវរក្សាឲ្យបាននូវបរិស្ថានធម្មជាតិ ជីវចម្រុះ ដែលមាននៅកន្លែងនោះ ហើយត្រូវតែអនុញ្ញាត ឲ្យសាធារណជនទាំងឡាយចេញចូលក្នុងបរិវេណនេះ នៅពេលក្រោយការកែលំអរួចហើយនោះ។

ជាការពិតណាស់ នៅជុំវិញបរិវេណ នៃព្រះវិហារនេះ មានរុក្ខជាតិចម្រុះ ដូចជាដើមឈើ វល្លិ៍ផ្កា ដើមប៉ប្រក់ អូគីដេរភ្នំ និងមានរុក្ខជាតិជាច្រើនមុខទៀត ដែលបានបញ្ចេញផ្កាយ៉ាងស្រស់ស្អាតនៅទីនោះ។

ព្រះវិហារកាតូលិកចំណាស់នៅក្នុងឧទ្យានជាតិព្រះមន្នីវង្ស នៅលើកំពូលភ្នំបូក-គោនេះ បានកសាងឡើងតាំងពីទសវត្សឆ្នាំ១៩២០ ក្នុងសម័យអាណានិគមនិយមបារាំង ធ្វើអាណាព្យាបាលលើកម្ពុជា និងបានបោះបងចោល តាំងពីប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល។

រាជរដ្ឋាភិបាល តាមរយៈក្រសួងបរិស្ថាន បានប្រគល់ព្រះវិហារនេះដល់ព្រះសហ-គមន៍កាតូលិកនៅកម្ពុជា គ្រប់គ្រង ជួសជុល ថែរក្សាវិញកាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ ក្នុងឱកាសដែលព្រះសហគមន៍កាតូលិកកំពុងប្រារព្ធពិធីបុណ្យអបអរសាទរព្រះយេស៊ូប្រសូត។ ពិធីនោះបានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់លោក សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងលោក អូលីវីយេ ឈ្មឺតហាស្លែរ អភិបាលព្រះសហ-គមន៍កាតូលិកភូមិភាគភ្នំពេញ៕

# បេក្ខជន៥៦នាក់ ទទួលពិធីត្រាស់ហៅយ៉ាងឱឡារិក



ថតដោយ សម្បត្តិ

បេក្ខជន បេក្ខនារី៥៦នាក់ ដែលមកពីមណ្ឌលសកម្មភាព កំពត កំពង់សោមភ្នំពេញខាងជើង ភ្នំពេញខាងត្បូង មណ្ឌលសកម្មភាពតាខ្មៅ និងមណ្ឌលសកម្មភាពភ្នំពេញថ្មី នៃភូមិភាគភ្នំពេញ បានទទួលការត្រាស់ហៅយ៉ាងឱឡារិក (ជំហ៊ានទីពីរ) ពីលោកអូលីវីយេ ឆ្មីតអីស្លែរ ដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹកនៅរាត្រីបុណ្យចម្លងខាងមុខ។

កម្មវិធីនេះធ្វើឡើងកាលពីថ្ងៃទី១៨ កុម្ភៈ ២០១៨ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល នៃមណ្ឌលសម្មភាពភ្នំពេញថ្មី ដោយមានគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ។

អ្នកស្រី ភោគ ម៉ានី តំណាងក្រុមគ្រូអប់រំជំនឿ បានស្នើសុំ និងបង្ហាញជូនលោកអភិបាលនូវអស់អ្នកដែលលោកត្រូវត្រាស់ហៅ ដោយថ្លែងថា បេក្ខជនទាំងនេះបានផ្ញើជីវិតលើព្រះហឫទ័យមេត្តាករុណាព្រះជាម្ចាស់។ សហគមន៍គ្រីស្តបរិស័ទគាំទ្រពួកគាត់ដោយពាក្យអធិដ្ឋានរបស់ខ្លួន និងដាស់តឿនពួកគេឲ្យខិតខំរស់នៅតាមដំណឹងល្អ។ អ្នកស្រីម៉ានី បន្ថែមថា បេក្ខជនទាំងនេះសូមឲ្យលោកអភិបាលទទួលពួកគាត់ក្នុងចំណោមអស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលាបថ្វាស និងអគ្គសញ្ញាអរព្រះគុណព្រះជាម្ចាស់នៅថ្ងៃបុណ្យចម្លងខាងមុខនេះ។ តំណាងគ្រូអប់រំជំនឿរូបនេះបញ្ជាក់ទៀតថា "យើងយល់ឃើញថា ពួកគាត់មានជំនឿល្អមឲ្យលោកត្រាស់ហៅគាត់មែន"។

បន្ទាប់ពីបានស្តាប់ពាក្យ ស្នើសុំ និងការអះអាងរបស់អតំណាងគ្រូអប់រំជំនឿរួចមក លោកអភិបាល បានសួរបញ្ជាក់ទៅកាន់ក្រុមបងធម៌ គ្រូអប់រំជំនឿ និងបូជាចារ្យហើយពួកគាត់បានបង្ហាញអំពីសក្ខីភាពនៃជំនឿរបស់បេក្ខជនទាំងអស់។

ក្រោយមកលោកអភិបាលបានសួរបញ្ជាក់បន្ថែមទៅកាន់បងប្អូនជាំបេក្ខជនបេក្ខនារីដែលត្រូវទទួលការត្រាស់ហៅ ឲ្យប្រកាសអំពីបំណងរបស់ខ្លួននៅចំពោះមុខព្រះសហគមន៍។ បេក្ខជនទាំង៥៦នាក់បានប្រកាសថា "ពិតជាចង់រួមក្នុងព្រះកាយព្រះគ្រីស្តដោយទទួលអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលាបថ្វាស និងអគ្គសញ្ញាអរព្រះគុណព្រះជាម្ចាស់ពិតមែន។

បន្ទាប់មក លោកអភិបាលបានត្រាស់ហៅបងប្អូន បេក្ខជន បេក្ខនារីតាមមណ្ឌលសកម្មភាពព្រះសហគមន៍នីមួយៗ ដើម្បីចុះឈ្មោះក្នុងបញ្ជី រួមជាមួយបងធម៌។ ក្រោយមកលោកអភិបាលលាបប្រេងក្នុងដៃបេក្ខជន បេក្ខនារីទាំងអស់ និងបំពាក់កន្សែងពណ៌ស្វាយ ដែលជាសញ្ញាថាបងប្អូនបានត្រៀមខ្លួន និងកែប្រែចិត្តគំនិតដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹកនារាត្រីបុណ្យចម្លងខាងមុខ។

លោកអភិបាលបានប្រកាសទទួលបេក្ខជនទាំងនោះ គ្រីស្តបរិស័ទទាំងអស់ក៏បានទះដៃអបអរសាទរ ស្វាគមន៍បងប្អូនដែលទើបតែទទួលពិធីត្រាស់ហៅជាឱឡារិក(ជំហ៊ានទីពីរ)។

លោកអភិបាលអូលីវីយេក៏បានមានប្រសាសន៍មកកាន់អ្នកយកព័ត៌មានយើងថា៖ ថ្ងៃនេះជាថ្ងៃមួយយ៉ាងពិសេសសម្រាប់ពិភពលោកទាំងមូល ដោយសារថ្ងៃទីមួយនៃរដូវ៤០ថ្ងៃ លោកអភិបាលក្នុងនាមព្រះសហគមន៍ត្រាស់ហៅបេក្ខជនឲ្យទទួលពិធីជ្រមុជទឹកនៅក្នុងថ្ងៃបុណ្យចម្លង ដែលមានន័យថាទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូ។ លោកបន្តថាថ្ងៃនេះភូមិភាគភ្នំពេញបានត្រាស់ហៅ ៥៦នាក់ និងកាលពីពីរថ្ងៃមុនបានត្រាស់ហៅបេក្ខជន ២០នាក់ នៅមណ្ឌលសកម្មភាពទន្លេបាសាក់ផងដែរ។

លោកបញ្ជាក់ថាទាំងអស់នេះណែនាំឲ្យព្រះសហគមន៍មានជីវិត ដោយសារព្រះសហគមន៍បានប្រកាសដំណឹងល្អ និងណែនាំឲ្យបងប្អូនខ្លះៗស្គាល់ ទទួលជីវិតថ្មី និងធ្វើដំណើរជាមួយព្រះយេស៊ូអស់មួយជីវិត។ លោកក៏បានផ្តាំផ្ញើទៅកាន់គ្រីស្តបរិស័ទ លោកបូជាចារ្យ និងបងធម៌ទាំងអស់ ត្រូវតែអធិដ្ឋានក្នុងអំណរសប្បាយដើម្បីបេក្ខជនដែលរៀបចំខ្លួនទទួលពិធីជ្រមុជទឹក ចេះតស៊ូ និងត្រៀមចិត្តគំនិតភ្ជាប់ជាមួយព្រះយេស៊ូពិតប្រាកដ ព្រមទាំងអាចនាំដំណឹងល្អទៅដល់អស់បងប្អូនឯទៀតឲ្យមានក្តីសង្ឃឹម។

ជាងនេះទៅទៀតលោកបានផ្តាំផ្ញើជាពិសេសដល់គ្រីស្តបរិស័ទនៃព្រះសហគមន៍ភូមិភាគភ្នំពេញទាំងមូលឲ្យយកចិត្តទុកដាក់តមអាហារ ចែករំលែកសេចក្តីស្រឡាញ់ពេលវេលា និងទ្រព្យសម្បត្តិដល់អស់អ្នកតូចតាច។

លោកអូលីវីយេបន្ថែមថា ជាពិសេសក្នុងឆ្នាំគ្រួសារ សូមអធិដ្ឋាន លើកទឹកចិត្តយកចិត្តទុកដាក់លើគ្រួសារដែលមានទុក្ខលំបាកផងដែរ។

បេក្ខជន ជុំ គឿន ជាជនពិការ ដែលរស់នៅក្នុងមណ្ឌលជនពិការបន្ទាយព្រាបបានឲ្យដឹងថា "ដោយហេតុបានឃើញគ្រីស្តបរិស័ទចេះស្រឡាញ់គ្នា ចេះចែករំលែកបទពិសោធន៍នៃជីវិតពិតៗឲ្យគ្នា ធ្វើឲ្យខ្ញុំពេញចិត្តហើយស្រឡាញ់ព្រះសហគមន៍ និងស្រឡាញ់ព្រះយេស៊ូ ទើបសម្រេចចិត្តចូលមកព្រះសហគមន៍កាតូលិកដើម្បីធ្វើជាគ្រីស្តបរិស័ទ"។

ព្រះសហគន៍កាតូលិកភូមិភាគភ្នំពេញបានត្រាស់ហៅបងប្អូនចំនួន ៥៦ នាក់ដើម្បីចុះឈ្មោះក្នុងបញ្ជីព្រះសហគមន៍ត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឱកាសបុណ្យចម្លងខាងមុខ។ ក្នុងរយៈពេល៤០ថ្ងៃមុនបុណ្យចម្លងនេះបងប្អូននឹងទទួលពិធីផ្សេងតាមក្បួនអប់រំជំនឿរបស់ព្រះសហគមន៍កាតូលិក ដូចជាពិធីទទួលធម៌ជឿ ធម៌ឱព្រះបិតា ពិធីជំរះចិត្តគំនិត និងបណ្តេញមារ។

*ដោយដាលីស*

# លោកអូលីវីយេលើកទឹកចិត្តឲ្យគ្រីស្តបរិស័ទក្នុងឆ្នាំថ្មី យកគំរូតាមគ្រួសារដ៏វិសុទ្ធ

ស្គរធំ និងឆាប់ បានប្រគំយ៉ាងរំពងតាមទម្រង់វង់ភ្លេងម៉ុងសាយចិន វៀតណាម នៅពេលវត្តមានរបស់លោកអភិបាល អូលីវីយេ បានឈានជើងដល់ក្លោងទ្វារភូមិគ្រីស្តបរិស័ទនៅចំប៉ា ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ កុម្ភៈ ២០១៨។ លោកបូជាចារ្យទទួលខុសត្រូវ និងគ្រីស្តបរិស័ទជាច្រើននាក់ ដែលរង់ចាំជាស្រេចហើយ បានមកទទួលស្វាគមន៍លោកអភិបាលដោយអំណរសប្បាយ និងឱឡារិក ហើយបន្តដំណើរមកកាន់ព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយ៉េ ដោយមានក្រុងម៉ុងសាយនាំមុខ។

ក្នុងពេលធ្វើដំណើរតាមដងផ្លូវចូលនោះ លោកអភិបាលបានប្រទានពរដល់បងប្អូនចំនួន ដែលមានផ្ទះតាមដងផ្លូវ ហើយមានគ្រីស្តបរិស័ទជាច្រើនក៏សម្រុកចូលមកទទួលព្រះពរផងដែរ។ ក្បួនដង្ហែរបន្តរហូតដល់ព្រះវិហារ ដែលមានគ្រីស្តជាច្រើនកំពុងរង់ចាំដែរនោះ បានទះដៃស្វាគមន៍គណៈអធិបតីយ៉ាងកងរំពង។

នៅមុខព្រះវិហារមានតុបតែងយ៉ាងស្អាត និងមានពាក្យស្លោក សួស្តីឆ្នាំថ្មីដែលសរសេរជាភាសាកំណើតរបស់គេ ចំណែកនៅខាងក្នុងក៏មានតុបតែងផ្កាភ្លីស្រស់បំព្រងដែលបង្ហាញថា ជាបុណ្យចូលឆ្នាំថ្មីប្រពៃណីចិន វៀតណាម។

ព្រះសហគមន៍កាតូលិកចំប៉ា ប្រារព្ធពិធីអភិបូជាអបអរសាទរឆ្នាំថ្មី ដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់ឆ្នាំចាស់កន្លងទៅ និងទូលអង្វរសុំសេចក្តីសុខសាន្តសម្រាប់ឆ្នាំថ្មី។

មុនចាប់ផ្តើមពិធីបុណ្យអភិបូជាក្រុមកុមារនៃព្រះសហគមន៍ចំប៉ាបានរាំរបាំដើម្បីអរព្រះគុណព្រះជាម្ចាស់ដែលបានថែរក្សាការពារ។

ក្នុងឱកាសនេះដែរ ពេលធម្មទេសនាលោកអភិបាល អូលីវិយេដែលជាអធិបតីបានបង្ហាញអំពីចំណាប់អារម្មណ៍ចំពោះអត្ថន័យនៃរបាំ និងបានបង្ហាញភាពរីករាយរួមជាមួយបងប្អូន។ លោកថាថ្ងៃនេះ យើងជូនពរ គ្នាទៅវិញទៅមក សូមឲ្យមានសេចក្តីសុខ សូមឲ្យគ្រួសារនីមួយៗបានប្រកបដោយ សុភមង្គល និងសេចក្តីសុខសាន្ត។

លោកអភិបាលអូលីវីយេ ក៏បានមានប្រសាសន៍ទៅកាន់បងប្អូនគ្រីស្តបរិស័ទទាំងអស់ នៅក្នុងឆ្នាំថ្មីនេះ សូមឲ្យយកគំរូតាម របៀបរស់នៅនៃគ្រួសារដ៏វិសុទ្ធ គឺត្រូវគោរពព្រះយេស៊ូដែលនៅលើឈើឆ្កាងជាគំរូ គោរពព្រះនាងម៉ារី ជាគំរូ និងគោរពសន្តយ៉ូសែបជាគំរូ។

លោកបន្ត ថា គ្រីស្តបរិស័ទត្រូវគោរពព្រះយេស៊ូនៅលើឈើឆ្កាងជាគំរូ ដែលព្រះអង្គបានលះបង់ចោលអ្វីៗទាំងអស់ ព្រោះតែសេចក្តីស្រឡាញ់ដ៏ពិតប្រាកដ ដោយបូជាព្រះជន្មផ្ទាល់របស់ព្រះអង្គ ដើម្បីឲ្យយើងមានជីវិត មានសេចក្តីសង្ឃឹម មានកម្លាំង និងសេចក្តីស្រឡាញ់ ដោយស្រឡាញ់គ្នាទៅវិញទៅមក។ គឺមិនគ្រាន់តែស្រឡាញ់ មនុស្សដែលយើងមាននិស្ស័យ តែត្រូវស្រឡាញ់ខ្មាំងសត្រូវ មនុស្សដែលយើងស្អប់ត្រូវលើកលែងទោសឲ្យគេផង ដូចព្រះយេស៊ូសូមព្រះបិតាលើកលែងទោសដល់សត្រូវដែលសម្លាប់ព្រះអង្គផងដែរ។

ចំពោះការគោរពព្រះនាងម៉ារីជាគំរូ លោកអភិបាលបញ្ជាក់ថា៖ ព្រះនាងម៉ារី គឺជាគ្រីស្តទូតដំបូង និងជាមាតារបស់យើងទាំងអស់គ្នា។ ព្រះនាងបានស្រឡាញ់ព្រះយេស៊ូជានិច្ច តាមរបៀបស្លូតបូត ដាក់ខ្លួនបម្រើ និងស្តាប់។ ព្រះនាងប្រាប់ឲ្យយើងកូនចៅ សូមស្តាប់ព្រះយេស៊ូទៅក្នុងឆ្នាំនេះ។

ជាចុងក្រោយលោករំឭកថា យើងត្រូវគោរពសន្តយ៉ូសែបជាគំរូព្រោះ ព្រះជាម្ចាស់បានជ្រើសរើសលោក ជាឲ្យធ្វើជាឪពុករបស់ព្រះយេស៊ូក្នុងលោកនេះ លោកស្រឡាញ់រក្សាការពារ គ្រួសារ កូន និងប្រពន្ធយ៉ាងល្អបំផុតឲ្យរស់នៅក្នុងសេចក្តីសុខសាន្តយ៉ាងបរិបូរណ៍។ លោកបញ្ជាក់ថា ហេតុនេះបុរសជាប្តី ជាឪពុកទាំងអស់ត្រូវយកចិត្តទុកដាក់ជាមួយប្រពន្ធកូន និងគ្រួសារតាមគំរូរបស់សន្តយ៉ូសែប ដើម្បីឲ្យគ្រួសារមានភាពរីកចម្រើន និងសុភមង្គល។

ដោយសារពិធីបុណ្យចូលឆ្នាំថ្មីនេះត្រូវក្នុងរដូវអប់រំពិសេស ហើយឆ្នាំនេះជាឆ្នាំគ្រួសារតាមគម្រោងការរបស់ព្រះសហគមន៍ផង លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ក៏បានណែនាំឲ្យគ្រួសារគ្រីស្តបរិស័ទនីមួយៗយកចិត្តទុកដាក់រួមគ្នាក្នុងគ្រួសារ អធិដ្ឋាន អានព្រះបន្ទូល និងរិះគិតស្មឹងស្មាធ ដើម្បីទទួលបានអត្ថន័យព្រះបន្ទូលដំណឹងល្អ។ លោកថា គ្រួសារពិតណាស់តែងជួបការលំបាកឧបសគ្គនានា និងបញ្ហាផ្សេងៗ។ ប៉ុន្តែយើងជឿលើគ្រួសារដ៏វិសុទ្ធ យកគំរូតាមគ្រួសារដ៏វិសុទ្ធ យើងទទួលកម្លាំ និងនាំឲ្យគ្រួសារយើងចម្រើនឡើង និងមានសេចក្តីសុខជានិច្ច។

មុនបញ្ចប់ពិធីបុណ្យក្រុមម៉ុងសាយ ប្រចាំព្រះសហគមន៍ នៃព្រះវិហារសន្ត ហ្វ្រង់ស្វ័រសាវីយ៉េ(ចំប៉ា)បានសម្តែង ជូនលោកអភិបាលទស្សនា ហើយលោកអភិបាលអូលីវីយេក៏បានចែកអំណោសប្បាយជាមួយបងប្អូន គឺជូនអាំងប៉ាវដល់អ្នកចូលរួមគ្រប់គ្នា ដោយនៅសំបកអាំងប៉ាវនោះមានរូបសញ្ញាឆ្នាំគ្រួសារ និងឃ្លាព្រះបន្ទូលថា "អ្នកមានចិត្តស្រឡាញ់ តែងតែអត់ឱនឲ្យជឿ សង្ឃឹម ទ្រាំទ្រ ក្នុងគ្រប់កាលៈទេសៈ" ដែលជាពាក្យស្លោកសម្រាប់ឆ្នាំគ្រួសារ៕



ថតដោយ លី សុវណ្ណា

# តំណាងសាសនាធំៗនៅក្នុងខេត្តព្រះសីហនុ ចូលរួមសួរសុខទុក្ខបងប្អូនជាប់ឃុំនៅមណ្ឌលអប់រំកែប្រែ ខេត្តព្រះសីហនុ


ថតដោយ លី សុវណ្ណា

ព្រះសហគមន៍កាតូលិកនៅខេត្តព្រះសីហនុ ដែលមានលោកបូជាចារ្យអ៊ុន សុន ជាអ្នកទទួលខុសត្រូវ បានរៀបចំដំណើរសួរសុខទុក្ខបងប្អូនជាប់ឃុំនៅមណ្ឌលអប់រំកែប្រែខេត្តព្រះសីហនុ កាលពីថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៨កន្លងទៅនេះ ដោយមានតំណាងសាសនាធំៗនៅក្នុងខេត្តព្រះសីហនុចូលរួមមានដូចជា ព្រះពុទ្ធសាសនាថេរវាទ ព្រះសហគមន៍កាតូលិក ក្រុមជំនុំ ព្រះពុទ្ធសាសនាមហាយាន និងឥស្លាមសាសនា។

ពិធីនេះបានប្រព្រឹត្តក្រោមអធិបតីភាពរបស់លោក អូលីវីយេ ស្មឹតអឺស្ល៊ែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ព្រះធម្មធម៌ចាន់ សុវណ្ណ មេគណខេត្តព្រះសីហនុ លោកឧត្តមអគារនុរក្សថ្នាក់លេខពីរ សំ សុផល ប្រធានមណ្ឌលអប់រំកែប្រែខេត្តព្រះសីហនុ។

ជាកិច្ចចាប់ផ្តើមកម្មវិធីលោក សំ សុផល ប្រធានមណ្ឌលអប់រំកែប្រែ ខេត្តបានមានមតិស្វាគមន៍គណៈប្រតិភូទាំងអស់យ៉ាងកក់ក្តៅ និងរាក់ទាក់ជាទីបំផុត។ លោកក៏បានអរគុណដល់ប្រតិភូសាសនាទាំងអស់ដែលបានយកចិត្តទុកដាក់ មកសួរសុខទុក្ខបងប្អូនជាប់ឃុំ តាំងពីឆ្នាំ២០១២មក។ ក្នុងពេលនោះលោកក៏បានរំលឹកដល់បងប្អូនជាប់ឃុំទាំងអស់ ឲ្យចិត្តទុកដាក់ស្តាប់ថេរដីកា និងប្រសាសន៍ប្រៀនប្រដៅនានារបស់មេដឹកនាំសាសនា។ យើងគ្មានអីតបស្នងសងគុណដល់ពួកគាត់មានតែស្តាប់ និងខិតខំកសាងខ្លួនឲ្យសើរឡើង កុំប្រព្រឹត្តបទល្មើសបន្ថែមទៀតក្នុងពន្ធនាគារ។ តាមប្រសាសន៍របស់លោកឧត្តមអគារនុរក្ស ជនជាប់ឃុំទាំងអស់មានចំនួនប្រមាណ១០៥២នាក់ ក្នុងនោះស្ត្រីមានចំនួន ១០២នាក់។

ព្រះសង្ឃ ចាន់ សុវណ្ណ មានសង្ឃដីកាថា សត្វលោកទាំងអស់សុទ្ធតែមានបំណងប្រាថ្នា សុច្ឆន្ទៈ ចង់មានសេចក្តីសុខទាំងផ្លូវកាយនិងផ្លូវចិត្ត។ តាមព្រះឱវាតរបស់ព្រះសាម្មាសម្ពុទ្ធបានប្រៀនប្រដៅ បើចង់បានសេចក្តីសុខត្រូវលះបង់សេចក្តីអាក្រក់ ដើម្បីទទួលបាននូវសេចក្តីសុខមកវិញ។ បុណ្យ មិនបានភ្លេចនូវម្ចាស់ដែលបានបំពេញទង្វើជាកុសលនោះឡើយ។ ចំពោះអំពើបាបក៏មិនបានបំភ្លេចនូវម្ចាស់ដែលបានប្រព្រឹត្តនូវអំពើបាប គឺបានទទួលបាននូវអ្វីដែលខ្លួនបានប្រព្រឹត្តដែរ។ លោកក៏បានពន្យល់អំពីអត្ថន័យនៃអភ័យទានផងដែរ ដែលជាប្រភពនៃសេចក្តីសុខ គឺការមិនលួច មិនសម្លាប់ មិនចងគំនុំគ្នាទៅវិញទៅមក។ ជាពិសេសលោកមានសង្ឃដីកាសង្កត់ធ្ងន់ថា "មានព្រះនៅក្នុងចិត្ត គឺយើងមានសេចក្តីសុខហើយ"។

ក្នុងពេលនោះដែរលោកអភិបាលព្រះសហគមន៍កាតូលិក អូលីវីយេ ស្មឹតអឺស្ល៊ែរ មានប្រសាសន៍ទៅកាន់បងប្អូនជាប់ឃុំអំពីអ្វីជាសេចក្តីសុខ។ តាមមនុស្សជា ច្រើន បានគិតថា សេចក្តីសុខគឺកើតមានដោយសារមានលុយច្រើន។ តែលោកអភិបាល បានមានប្រសាសន៍ថា សេចក្តីសុខគឺមានបានដោយសារតែយើងមានសេចក្តីស្រឡាញ់។ លោកបន្តថា មានមនុស្សជាច្រើនបានឲ្យតម្លៃសេចក្តីសុខលើលុយ គឺមានលុយ មានសេចក្តីសុខ។ តែដើម្បីមានលុយត្រូវការ ធ្វើការច្រើន គ្មានពេលវេលាល្មមដើម្បីនៅជាមួយក្រុមគ្រួសារប៉ុន្មានទេ។ មានអ្វីផ្សេងទៀត ដោយដឹងថា មានគេស្រឡាញ់យើង មានគេយកចិត្តទុកដាក់នឹងយើង លើកទឹកចិត្តយើង គេស្តាប់យើង គេចាប់អារម្មណ៍លើយើង មានគេនឹកយើង។ លោកន្ថែមថា សេចក្តីសុខចេញពីសេរីភាព។ បងប្អូនមានសេរីភាពនៅទីនេះ តែតាមរូបកាយបងប្អូនមានព្រំដែន។ ប៉ុន្តែបងអាចកសាងសេរីភាពក្នុងខ្លួនម្នាក់ៗ តាមផ្លូវចិត្ត តើខ្ញុំរៀបចំខ្លួនដូចម្តេច នៅក្នុងមណ្ឌលអប់រំកែប្រែនេះ ធ្វើជាមនុស្សល្អទៅៗ គឺយើងត្រូវជួយគ្នាទៅវិញទៅមក លើកទឹកចិត្តគ្នាទៅវិញទៅមក។ លោកអភិបាលបន្តថា ពេលនេះមានមេដឹកនាំសាសនាទាំងអស់មកជួបបងប្អូន ជាមហាគ្រួសារតែមួយ ចែកសេចក្តីស្រលាញ់ជាមួយបងប្អូន។ បងប្អូននៅទីនេះប្រហែលគិតថាឯកា គ្មាននរណារវីរវល់តទៅទៀត តែកុំភ្លេចយើងមានព្រះ។ តាមព្រះពុទ្ធសាសនា យើងមានព្រះធម៌។ គ្រីស្តសាសនា មានព្រះយេស៊ូដែលស្រលាញ់យើង។ ឥស្លាមសាសនាមានអាឡោះដែលលើកទឹកចិត្តយើង មានព្រះជាម្ចាស់ដែលបានបង្កើតយើងជាបុរស ជាស្ត្រីដើម្បីមានសេចក្តីសុខនៅក្នុងសេចក្តីស្រឡាញ់។ ទាំងនេះជាកម្លាំងពិសេសសម្រាប់យើង។ ពេលខ្លះមិនចេះនិយាយគ្នាសូមនិយាយទៅព្រះទៅ ដើម្បីលើកទឹកចិត្តយើង។

បន្ទាប់ពីសំណេះសំណាលជាមួយបងប្អូនជាប់ឃុំ ព្រះសង្ឃបានសូត្រធម៌បោះព្រំលើបងប្អូន ហើយតាមកាតូលិកលោកអភិបាល រួមនិងគ្រីស្តបរិស័ទទាំងអស់អធិដ្ឋាន និងបាចទឹកព្រះពរលើបងប្អូនផងដែរ។ ក្រោយមកក៏មានចែកអាហារជានិងមិត្តរូបដល់បងប្អូន និងសម្ភារៈមួយចំនួនសម្រាប់កុមារដែលស្នាក់នៅជាមួយម្តាយដែលជាប់ឃុំ។

ព្រះសហគមន៍កាតូលិកក្នុងនៅប្រទេសកម្ពុជាយកចិត្តទុកដាក់យ៉ាងខ្លាំងលើកិច្ចការសន្ទនាជាអន្តរសាសនា ដើម្បីសុខដុមរមនីយ៍កម្មសាសនា និងសន្តិភាពក្នុងប្រទេសក្នុងតំបន់ និងពិភពលោកទាំងមូល៕

# សម្ព័ន្ធអង្គការកាតូលិក ដើម្បីមេត្តាករុណានិងការអភិវឌ្ឍ ឈ្វេងយល់អំពីការការពារបរិស្ថានធម្មជាតិ

សម្ព័ន្ធអង្គការកាតូលិក ដើម្បីមេត្តាករុណា និងការអភិវឌ្ឍចំនួនជាង២០ស្ថាប័នបានជួបជុំក្នុងជំនួបប្រចាំឆ្នាំរបស់ខ្លួន កាលពីថ្ងៃទី១៥ មករា ២០១៨។ ការជួបជុំនេះ បានប្រព្រឹត្តទៅនៅមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកភ្នំពេញថ្មី ក្រោមអធិបតីភាពលោកអូលីវីយេ ដ្មឹតអីស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងលោកវ័ន្ធ វីរៈ ទីប្រឹក្សានៃក្រសួងបរិស្ថាន។ កិច្ចប្រជុំនេះបានរិះគិតលើប្រធានបទអំពីការការពារបរិស្ថាន "Laudato Si" and the Journey to care for Enviroment ដោយមានការណែនាំដោយវាគ្មិន សំខាន់ៗមកក្រសួងបរិស្ថាន និងលោកបូជាចារ្យកាព្រីអែល មកពីក្រុមគ្រួសារសហជីវិនព្រះយេស៊ូ។

ជាកិច្ចស្វាគមន៍លោក អូលីវីយេ ជាអធិបតី បានមានប្រសាសន៍ស្វាគមន៍ ប្រកបដោយភាពកក់ក្ដៅចំពោះវត្តមាននៃតំណាងអង្គការទាំងអស់ដែលបានអញ្ជើញចូលរួម។ លោកថានេះជាអំណរសប្បាយដែលជួបជុំគ្នាប្រចាំឆ្នាំ។ ពេលជួបជុំគ្នាយើងតែងរិះគិតលើប្រធានបទមួយ ថ្ងៃនេះយើងរិះគិតអំពីធម្មជាតិ និងបរិស្ថាន។ លោកបន្តថា ព្រះសហគមន៍កំនត់យកឆ្នាំនេះជាឆ្នាំគ្រួសារ ពិតណាស់វាមានការទាក់ទងគ្នា។ គ្រួសារនីមួយៗរស់យ៉ាងជិតស្និទ្ធនឹងបរិស្ថានធម្មជាតិ ដែលជាព្រះអំណោយទានរបស់ព្រះជាម្ចាស់។ នាំឲ្យយើងនឹកឃើញព្រះជាម្ចាស់ ប្រទានឲ្យគ្រួសារដំបូងបង្កើតកូនចៅដូចហ្វូងផ្កាយនៅលើមេឃ និងទទួលខុសត្រូវទាំងស្រុងលើធម្មជាតិ និងបរិស្ថាន។ សព្វថ្ងៃនេះមាតាបិតាទាំងអស់មានតួនាទីអប់រំកូនចៅឲ្យស្រឡាញ់បរិស្ថាន។ ក្នុងនោះដែរដោយមានវត្តមានមន្ត្រីជាន់ខ្ពស់នៃក្រសួងបរិស្ថាន លោកអភិបាលក៏បានថ្លែងអំណរគុណម្តងទៀតដែលរាជរដ្ឋាភិបាលតាមរយៈក្រសួងបរិស្ថានបានប្រគល់វិហារដ៏ចំណាស់លើភ្នំបូកគោ ឲ្យមកព្រះសហគមន៍ដើម្បីថែរក្សា និងកាន់កាប់ទុកជាប្រយោជន៍ប្រតិបត្តិតាមជំនឿសាសនា។

ក្នុងពេលនេះដែរលោកបូជាចារ្យ កាព្រីអែល មកពីក្រុមគ្រួសារសហជីវិនព្រះយេស៊ូ បានបង្ហាញចំនុចមួយចំនួននៅក្នុសារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ដែលមានចំណងជើងថា "សូមកោតសរសើរព្រះជាម្ចាស់របស់ខ្ញុំ" ដែលជាលិខិតដែលវែងជាងគេចំណោមលិខិតទាំងឡាយរបស់សម្តេចប៉ាប ដែលរិះគិតអំពីបរិស្ថានធម្មជាតិ។ លោកបូជាចារ្យបានលើកយកជំពូកទីមួយមកនិយាយដែលសម្តេចប៉ាបលើកឡើងថា "យើងមានបញ្ហា" គឺយើងមើលមិនឃើញអ្វីៗដែលបានកើតឡើងនៅជុំវិញពិភពលោកទាំងមូល។ ហើយសកម្មភាពតូចៗជាច្រើនអាចធ្វើឲ្យមានឥទ្ធិពលយ៉ាងខ្លាំង។ អ្នកដែលនឹងរងគ្រោះពីឥទ្ធិពលនេះមុនគេ និងខ្លាំងជាងគេគឺអ្នកក្រីក្រជាងគេ។ ក្នុងលិខិតនេះដែរចំណុចដែលជាបញ្ហា គឺយើងទាំងអស់គ្នា មិនចេះប្រើកម្លាំង ឬបច្ចេកទេសដែលយើងមានដោយយុត្តិធម៌ ប្រាជ្ញា និង មនសិការ។ លោកបូជាចារ្យក៏បានលើកឡើងនូវគន្លឹះដែលយើងម្នាក់ៗតែយកចិត្តទុកដាក់គឺរុក្ខជាតិ សត្វ និងអ្វីៗទាំងអស់ព្រះជាម្ចាស់ជាអ្នកបង្កើតវាមានតម្លៃ និងឯករាជ្យភាពរបស់វា។ យើងទាំងអស់គ្នាត្រូវបានរួមបញ្ចូលយ៉ាងជិតស្និទ្ធជាមួយគ្នា។

បញ្ហាសង្គម និងបរិស្ថានគឺជាបញ្ហាតែមួយ។ ហេតុនេះម្នាក់ៗអាចធ្វើបានចំពោះកិច្ចការរួម គឺយកពេលខ្លះគយគន់សោភ័ណភាពនៅជុំវិញខ្លួន។ អ្វីៗដែលបង្រៀននិងរៀនក្នុងក្រុមគ្រួសារ គឺមានសារៈសំខាន់សម្រាប់សង្គមរបស់យើង។ សកម្មភាពនៃការបង្ការ និងការពារបរិស្ថាន គឺជាការងារដ៏ថ្លៃថ្នូមួយ។ សូមពិនិត្យមើលវប្បធម៌ទំនើបមិនកុំឆាប់ទទួលអ្វី ដែលអ្នកមើលឃើញក្នុងសង្គមថាល្អ ១០០%។ សូមពិនិត្យមើលបែបផែននៃជីវិតរស់នៅផ្ទាល់ខ្លួន។ តើរបៀបដែលអ្នកធ្វើប៉ះពាល់ដល់បរិស្ថាន និងអ្នកដទៃឬទេ?។

អង្គប្រជុំក៏បានឈ្វេងយល់អំពីផែនការសកម្មភាពជាតិស្តីពីបរិស្ថាន ឆ្នាំ២០១៦-២០២៣ ដែលមានគោលដៅយុទ្ធសាស្ត្រជំរុញការកែទម្រង់ស៊ីជម្រៅនិងការធ្វើទំនើបកម្មការគ្រប់គ្រង និងការអភិរក្សបរិស្ថាន និងធនធានធម្មជាតិតាមរយៈសកម្មភាពមានផែនការច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវ ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនិងផលិតភាពនៃការប្រើប្រាស់ធនធាន យន្តការហិរញ្ញប្បទាននិរន្តភាព និងកាត់បន្ថយកាកសំណល់ និងការបំពុល ព្រមទាំងធ្វើឲ្យប្រសើរឡើងនូវសុខមាលភាពប្រជាពលរដ្ឋ។ ការបង្វែរការគ្រប់គ្រង និងផ្តល់ជូនដីសប្បទានសេដ្ឋកិច្ចទៅក្នុងសមត្ថកិច្ចរបស់ក្រសួងកសិកម្មក៏ជាផ្នែកមួយនៃកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងបរិស្ថានដែរ ដើម្បីធ្វើឲ្យមានភាពច្បាសលាស់។ ក្រសួងបរិស្ថានគ្រប់គ្រងតែតំបន់ព្រៃអភិរក្ស និងឧទ្យានជាតិ ដែលសព្វថ្ងៃមានផ្ទៃដីប្រមាណជា ២លានហិតា។ ក្នុងស្មារតីនៃការពារថែរក្សាបរិស្ថាន។ សិក្ខាកាមទាំងអស់មិនគ្រាន់តែអង្គុយស្តាប់ទទួលយកខ្លឹមសារនៃបទបង្ហាញជាទ្រឹស្តីគឺបានរួមគ្នាដាំដើមឈើរួមគ្នាផងដែរ ក្នុងបរិវេណនៃមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកភ្នំពេញថ្មី នៃភូមិភាគភ្នំពេញក្នុងបរិយាកាសសប្បាយរីករាយនិងស្និទ្ធស្នាល។

គួរបញ្ជាក់ថា សម្ព័ន្ធអង្គការកាតូលិក ដើម្បីមេត្តាករុណា និងការអភិវឌ្ឍ តែងតែជួបប្រជុំគ្នាជាប្រចាំ ចំនួន៣ដងក្នុងមួយឆ្នាំ ដើម្បីចែករំលែកអំណរសប្បាយ និងភាតរភាពរវាងគ្នានិងគ្នា។ ក្នុងអង្គប្រជុំនីមួយៗតែងរិះគិតទៅលើប្រធានផ្សេងៗ ដែលស៊ីជម្រៅទៅនឹងបេសកកម្មរបស់ខ្លួនកំពុងបំពេញនៅក្នុងប្រទេសកម្ពុជា ៕

*ដោយ លី សុវណ្ណា*



ថតដោយ លី សុវណ្ណា

# សម្ដេចប៉ាបលើកទឹកចិត្តក្រុមសាន់តាម៉ាតា ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីចុងសប្ដាហ៍មុនបានបង្ហាញអំពីការគាំទ្រ និងលើកទឹកចិត្ត ក្រុមសាន់តា ម៉ាតា ដែលជាក្រុមមួយដែលបានបង្កើតឡើងតាំងតែពីឆ្នាំ២០១៤ ឲ្យបន្តបេសកម្មនៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

សម្ដេចប៉ាបបានថ្លែងទៅកាន់សមាជិកនៃក្រុមនេះ នៅក្នុងជំនួបកាលពីថ្ងៃទី០៩ ខែកុម្ភៈ ក្រោយពេលដែលសមាជិកក្រុមនេះបានជួបជុំគ្នា ប្រជុំពិភាក្សារយៈពេល ២ ថ្ងៃ នៅបុរីវ៉ាទីកង់ អំពីសកម្មភាពនៅក្នុងការទប់ស្កាត់ការជួញដូរមនុស្ស។

សម្ដេចប៉ាបបានមានប្រសាសន៍ថា "បទពិសោធបង្ហាញថាទាសភាពសម័យទំនើបបែបនេះមានលក្ខណៈទូលំទូលាយជាងការគិតទុកជាមុនសូម្បីតែរឿងអាស្រូវ និងភាពខ្មាស់អៀនរបស់យើង-ដោយការរីកចំរើននៃសង្គមរបស់យើង"។

សម្ដេចប៉ាបក៏បានថ្លែងទៀតថា ក្នុងនាមជាអ្នកដឹកនាំការអនុវត្តច្បាប់គោលនយោបាយស្រាវជ្រាវ និងគោលនយោបាយសាធារណៈ និងជំនួយគ្រូគង្វាលអ្នកផ្ដល់ការរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយបុព្វហេតុ និងផលប៉ះពាល់នៃវិបត្តិសម័យទំនើបនេះដែលបន្តបង្កឱ្យមានការឈឺចាប់ដល់មនុស្សជាបន្តបន្ទាប់។

គួររំលឹកថា ក្រុម សាន់តា ម៉ាតា នេះត្រូវបានគេដឹងថា គឺជាសម្ព័ន្ធនៃថ្នាក់ដឹកនាំប៉ូលីសអន្តរជាតិនិងក្រុមលោកអភិបាលនៃព្រះសហគមន៍កាតូលិក មកពីជុំវិញពិភពលោកដែលធ្វើការជាមួយសង្គមស៊ីវិលនៅក្នុងដំណើរការមួយដែលត្រូវបានអនុម័តដោយ សម្ដេចប៉ាប ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងទាសភាពសម័យទំនើប។

ការជួបប្រជុំគ្នានៅសប្ដាហ៍កន្លងទៅនេះ គឺជាជំនួបលើកទី ៥ សម្រាប់ក្រុមនេះ ដោយឆ្នាំនេះ បណ្ដាអ្នកចូលរួម មានផ្ដោតការពិភាក្សាជាពិសេស ទៅលើបញ្ចូលសកម្មភាពគ្រប់ទីបទាំងអស់ ការពិភាក្សាផ្លាស់ប្ដូរនូវបទពិសោធន៍របស់ពួកគេទាំងភាពជោគជ័យនិងបញ្ហាប្រឈមដែលការប្រឈមនេះត្រូវបានចាត់ទុកជាអាទិភាពនៅក្នុងប្រទេសជិតខាងដែលបញ្ហាប្រឈមស្រដៀងគ្នា៕

# សម្ដេចប៉ាបៈ ព្រះជាម្ចាស់តែមួយគឺគ្រប់គ្រាន់ដើម្បីផ្ដល់ឲ្យយើងនូវសុភមង្គលដ៏បរិបូណ៌

ថ្លែងកាលពីថ្ងៃអាទិត្យ ដែលជាសប្ដាហ៍ទីមួយនៃរដូវជំណមសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងសង្កត់ធ្ងន់រំលឹកគ្រីស្តបរិស័ទជាថ្មីទៀតថា បើយើងមានព្រះជាម្ចាស់នៅក្នុងចិត្ត យើង នឹងមានសុភមង្គល និងភាពស្ងប់ស្ងាត់នៅក្នុងចិត្ត និងសកម្មភាពរបស់យើង ។

សម្ដេចប៉ាបបានថ្លែងថា នៅលើពិភពលោកនេះមានរឿងរន្ធត់មានរឿងសោកសង្រេង មានរឿងវេទនា គ្រប់យ៉ាង ដូច្នេះសូមរក្សាចិត្តនិងបើកចិត្តឲ្យទូលាយដើម្បីយាងព្រះជា ម្ចាស់មកចូលក្នុងចិត្តរបស់យើង ដើម្បីឲ្យយើងមានភាពស្ងប់ស្ងាត់ និង មានសន្តិភាព នៅក្នុងចិត្ត។

សម្ដេចប៉ាបក៏បានបំភ្លឺទៀតថា នៅក្នុងជីវិតរបស់មនុស្ស គឺគ្រប់គ្នា តែតែឆ្លងកាត់នូវ រស់ជាតិជីវិតបែបនេះ រាល់ពេលរាល់ថ្ងៃរាល់វេលាប៉ុន្តែសូមអធិដ្ឋានព្រះជាម្ចាស់ទ្រង់អាច ជួយយើងឲ្យមានភាពស្ងប់ចិត្ត ។

សម្ដេចប៉ាបបានថ្លែងទៀតថា ជីវិតរបស់យើងពិតជាមិនអាចដំណើរការតាមការចង់បាន របស់យើងទាំងអស់នោះទេ ប៉ុន្តែ ព្រះជាម្ចាស់ ទ្រង់អាចគង់នៅក្នុងចិត្តយើង កុំឲ្យ គិតតែ បញ្ហានេះ ហើយនឹងនាំឲ្យយើងមានចិត្តបើកចំហរ ហើយគំនិតទទួលគំនិតអ្នកដ៏ទៃ ដើម្បី ឲ្យយ៉ាងអាចនឹងទទួលបាននូវអ្វីដែលបានបានធ្វើ។

សម្ដេចប៉ាបបានថ្លែងបញ្ជាក់ថា សូមជឿ លើព្រះជាម្ចាស់ ទ្រង់នឹងគង់នៅជាមួយនឹងយើងទាំងអស់គ្នា រិះគិតជាមួយនឹងយើងទាំងអស់គ្នា ដើម្បីសង្គម ដើម្បីសកម្មភាពគ្រប់យ៉ាងនៅ ក្នុងសង្គម៕

# អតីតសម្ដេចប៉ាបប៉ូលទី៦ នឹងក្លាយជាសន្តបុគ្គលក្នុងពេលឆាប់ៗនេះ

តាមសេចក្ដីរាយការណ៍របស់វិទ្យុវ៉ាទីកង់បានឲ្យដឹងថា អតីតសម្ដេចប៉ាបប៉ូលទី៦ នឹងត្រូវបានតែងតាំងជាសន្តបុគ្គលក្នុងពេលឆាប់ៗនេះ បន្ទាប់ពីមានការអស្ចារ្យលើកទី២ ត្រូវបានបង្ហាញដោយស្ត្រីម្នាក់នៅវេរ៉ូណា ( Verona )នៅប្រទេសអ៊ីតាលី។ ស្ត្រីនោះត្រូវបានក្រុមគ្រូពេទ្យឲ្យដឹងថា គាត់មានជំងឺដែលមិនអាចបង្កើតកូនដែលនៅក្នុងផ្ទៃអាយុបានប្រាំខែនោះឡើយ។ ហើយគ្រូពេទ្យរបស់គាត់ បានឲ្យគាត់ពន្លូតកូននោះចេញ។ រឿងរ៉ាវនេះបានកើតឡើងក្នុងឆ្នាំ២០១៤ ក្នុងខែតុលា។ ស្ត្រីជាម្ដាយរូបនោះ ក៏បានអធិដ្ឋាននៅមុខទីសក្ការបូជាព្រះនាងម៉ារីនៃភ្លើសន្ទោស ដើម្បីអធិដ្ឋានអង្វរដល់អតីតសម្ដេចប៉ាបប៉ូលទី៦។ ជាការឆ្លើយតបទារិកានោះបានសម្រាលមកដោយសុខភាពល្អហើយរស់នៅដោយសុខភាពប្រសើរហូតមកដល់ពេលបច្ចុប្បន្ននេះ។

ប្រភពដដែលបានឲ្យដឹងថា ក្រុមគ្រូពេទ្យមិនអាចបញ្ជាក់អំពីការព្យាបាលនៃជំងឺរបស់ស្ត្រីជាម្ដាយរូបនេះបានឡើយ ប៉ុន្តែក្រុមអ្នកប្រឹក្សានៃទេវវិទ្យាបានយល់ឃើញថានេះជាការអស្ចារ្យនៃជំនឿតាមរយៈការអង្វរសម្ដេចប៉ាបប៉ូលទី៦។

ក្រុមលោកកាឌីណាល់នៃក្រសួងសម្រាប់សន្តបុគ្គល បានរៀបចំកិច្ចប្រជុំកាលពីថ្ងៃអង្គារសប្ដាហ៍នេះ (៦ កុម្ភៈ) ជាជំហានចុងក្រោយ ហើយនឹងត្រូវបានដាក់ជូនសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ពិនិត្យ និងអនុម័ត។

ការអស្ចារ្យលើកទី១របស់អតីតសម្ដេចប៉ាបប៉ូលទី៦ កើតឡើងកាលពីឆ្នាំ១៩៩៣ នៅសហរដ្ឋអាមេរិក។ ស្ត្រីម្នាក់មានកូនក្នុងផ្ទៃត្រូវបានគ្រូពេទ្យពិនិត្យឃើញថាទារកនោះមានជំងឺ ជំងឺផ្នែកខួរក្បាលធ្ងន់ធ្ងរ។ គេបានស្នើសុំឲ្យកូនពន្លូតកូននោះចេញ តែម្ដាយនោះបានអង្វរដោយមានការជឿជាក់ទាំងស្រុងទៅកាន់អតីតសម្ដេចប៉ាបប៉ូលទី៦។

ការអស្ចារ្យលើកដំបូងនេះ ត្រូវបានសម្ដេចប៉ាបបេណេឌិកតូទី១៦ បច្ចុប្បន្នជាសម្ដេចប៉ាបចូលនិវត្ត បានអនុម័តទទួលស្គាល់កាលពីខែតុលា ឆ្នាំ២០១៤កន្លងទៅ។

អតីតសម្ដេចប៉ាបប៉ូលទី៦ កើតនៅឆ្នាំ១៨៩៧ នៅទីក្រុងខនសេស្សូ (Concesio) ក្នុងតំបន់ លំបារឌី (Lombardy) នៃប្រទេសអ៊ីតាលី។ គាត់ត្រូវបានតែងតាំងជាបូជាចារ្យនៅអាយុ ២២ឆ្នាំ ហើយបានបម្រើការងារនៅអគ្គភូមិភាគមីឡានមុនពេលការបោះឆ្នោតជ្រើសរើសសម្ដេចប៉ាបនៅឆ្នាំ១៩៦៣។ គាត់បានស្លាប់នៅឆ្នាំ១៩៧៨។

ក្នុងនាមជាសម្ដេចប៉ាប លោកបានត្រួសត្រាយដឹកនាំអង្គមហាសន្និបាតវ៉ាទីកង់ទីពីរ ដែលត្រូវបានបើកដោយសម្ដេចប៉ាបយ៉ូហានទី២៣។ គាត់ក៏បានប្រកាសឱ្យប្រើនូវរបៀបនៃការគោរពពិធីបុណ្យថ្មីរបស់ព្រះសហគមន៍កាតូលិកនៅឆ្នាំ១៩៦៩ ផងដែរ។

សម្ដេចប៉ាបប៉ូលទី៦ បោះពុម្ពផ្សាយសារលិខិតអូម៉ាណាអេវីតេ( Humanae Vitae ) ដែលប្រែថាតម្លៃនៃជីវិតមនុស្សក្នុងឆ្នាំ 1968 ដែលបានបញ្ជាក់សាជាថ្មីអំពីការបង្រៀនរបស់ព្រះសហគមន៍កាតូលិកប្រឆាំងនឹងការពន្យាកំណើត ហើយរំលឹកជាថ្មីនូវព្រហ្មចារីភាពជាបូជាចារ្យកាតូលិក៕

# លោកអភិបាលនៃព្រះសហគមន៍កាតូលិក ៣ ប្រទេស ទស្សនៈកិច្ច លីមីណា

ក្រុមលោកអភិបាលនៃព្រះសហគមន៍កាតូលិកចំនួន ៣ ប្រទេស សរុប ១៤ រូប បានទទួលការអនុញ្ញាតជួបពិភាក្សាជាមួយនឹងសម្ដេចប៉ាប ។

ទីភ្នាក់ងារព័ត៌មានហ្វីដែស បានរាយការណ៍ថា ជំនួបនេះ គឺបានដំណើរការកាលពីថ្ងៃទី០៨ ខែកុម្ភៈ ហើយក្រុមលោកអភិបាលទាំង ១៤រូបនោះ គឺមកពី ប្រទេស ម៉ាឡេស៊ី សិង្ហបុរី និង ប្រុយណេរ ។

ការិយាល័យសារព័ត៌មាននៃព្រះសហគមន៍កាតូលិកប្រចាំនៅបុរីវ៉ាទីកង់ បានរាយការណ៍អំពីខ្លឹមសារនៃកិច្ចប្រជុំនោះតាមរយៈសេចក្ដីប្រកាសព័ត៌មានមួយដែលចេញផ្សាយក្រោយ ជំនួបនោះ។

គួររំលឹកថា ព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសទាំងបីនេះ គឺមានសរុប ប្រមាណជា ១,១៧លាននាក់ នៅក្នុងនោះនៅម៉ាឡេស៊ី មាន ៨៥០,០០០ នាក់ ។ សិង្ហបុរីមានចំនួន ប្រមាណជា ៣០៣,០០០ ហើយនៅប្រុយណេរ គឺមាន ២១,០០០នាក់៕

# ការងារចាត់តាំងរបស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ២០១៨-២០២១

## តំបន់ទន្លេមេគង្គ



លោកបូជាចារ្យ **ស៊ីព្រាមុងវីរៈជ័យ** (TMS)
ទទួលខុសត្រូវតំបន់សកម្មភាពមេគង្គ



លោកបូជាចារ្យ **វណ្ណាថាយ៉ាន អារ៉ូគីយ៉ាដុស្ស** (MEP) ជាសហការី



លោកបូជាចារ្យ **ដានីអែល យុន** (TMS)
ជាសហការី

## តំបន់តាខ្មៅ



លោកបូជាចារ្យ **ហ្វ្រង់ស្វ័រ សាវីយេ ឌីម៉ុង** (MEP)
ទទួលខុសត្រូវតំបន់សកម្មភាពតាខ្មៅ



លោកបូជាចារ្យ **ទូលីញ៉ូ ជីអីវ៉ាន់នី** (PIME)
ជាសហការី

## តំបន់ទន្លេបាសាក់



លោកបូជាចារ្យ **សិលា ឡូវ៉ាន់ធីន**
ទទួលខុសត្រូវតំបន់សកម្មភាព
ទន្លេបាសាក់



លោកបូជាចារ្យ **ដាវ ទៀនដុង**
(ហ្វ្រង់ស៊ីស្កែន) ជាសហការី



លោកបូជាចារ្យ **ព្រាស្វ៊ត សែនចាន់ នីកុន**
ជាសហការី



លោកបូជាចារ្យ **ប៉ូលរឿន ឆ័ត្រសិរី** (TMS) ទទួលមុខងារពីសភាលោកអភិបាល ឡាវ និងកម្ពុជា ជាតំណាងផ្នែកវិនិច្ឆ័យក្តីរបស់តុលាការអន្តរភូមិភាគឡាវ និងកម្ពុជា



លោកបូជាចារ្យ **បេនីតេស ហ្វូស្តាវ៉ូ** (PIME) ចាត់តាំងដោយលោកអភិបាល ជាអ្នកទទួលខុសត្រូវលើយុវជនអន្តរភូមិភាគ



លោកបូជាចារ្យ **អារ៉ាំងហ្គោ ហ្វេរណាន់ដូ**



លោកបូជាចារ្យ **ឆាលេ លេឈីផ៉ន**
(YARUMAL)

តំណាងលោកអភិបាល សម្រាប់ណែនាំយុវជន និងកូន ជំទង់ និងកុមារ



លោកបូជាចារ្យ **ទូលីញ៉ូ ជីអីវ៉ាន់នី** (PIME) ជាតំណាងលោកអភិបាល សម្រាប់គណៈកម្មការព្រះគម្ពីរ



លោកបូជាចារ្យ **ហ្សារនី ដាមីញ៉ាំង** (MEP)
ទទួលខុសត្រូវនិស្សិតកាតូលិកនៅភ្នំពេញ



លោកបូជាចារ្យ **សិលា សួន ហាង្សលី** ជាតំណាងលោកអភិបាល និងទទួលខុសត្រូវខាងសុខាភិបាល និងទំនាក់ ទំនងជាមួយរដ្ឋាភិបាល



លោក**ផុន សុផល** ទទួលមុខងារនាយកវិទ្យាស្ថានសន្តប៉ូល (តាកែវ) មានការទទួលស្គាល់ពីក្រសួងអប់រំយុវជន និងកីឡា



លោក **ស៊ាន់ សារឿន** ទទួលខុសត្រូវការិយាល័យយុវជន ជំទង់ និងកុមារ



លោក **យុន សំអាត** ទទួលមុខងារនាយកវិទ្យាល័យបច្ចេកទេសសន្ត ហ្វ្រង់ស្វ័រ (តាកែវ-អង្គតាសោម)



អ្នកស្រី **ខ្សៃ មករា** ទទួលមុខងារនាយិកាសាលាបឋមសិក្សា និងសិល្បៈ សន្ត ហ្វ្រង់ស្វ័រ (តាកែវ-ចម្ការទៀង)

# រូបភាពសកម្មភាពរបស់ព្រះសហគមន៍



អបអរសាទរបុណ្យរំលឹកខួប២២៨ឆ្នាំ នៃព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង



ពិធីថ្វាយអភិបូជាសម្រាប់ចាស់ៗ នៅព្រះសហគមន៍កាតូលិក សន្តយ៉ូសែប ផ្សារតូច



ពិធីបុណ្យ អរព្រះគុណព្រះជាម្ចាស់សម្រាប់ ភោគផល ដែលទទួលបាន ពេញមួយឆ្នាំ នៅព្រះសហគមន៍កាតូលិក ចំណោម



ពិធីថ្វាយអភិបូជាបើកឆ្នាំ គ្រួសារ



ពិធីត្រាស់ហៅយ៉ាងឱឡារិក នៅព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម



បុណ្យរោយផេះ នៅព្រះសហគមន៍កាតូលិកព្រះកុមារយេស៊ូ បឹងទំពុន



បណ្ណាល័យព្រះសហគមន៍កាតូលិកកំពង់ចាម បានធ្វើសកម្មភាពជាមួយក្មេងៗ នៅតាមភូមិប្រចាំថ្ងៃ និងនៅតាមទីកន្លែងនីមួយៗ



បុណ្យរោយផេះ នៅព្រះសហគមន៍កាតូលិកសន្តយ៉ូសែប ផ្សារតូច


Radio Veritas Asia

Khmer Service

RADIO VERITAS ASIA-KHMER SERVICE

# វិទ្យុវីរីតាស់អាស៊ីខេមរភាសា

## សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

### ✣ ផ្សាយតាមរលកធាតុអាកាស FM

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ រាល់ថ្ងៃ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៨:០០- ៩:០០ រាល់ថ្ងៃ |
| សៀមរាប | : FM 98.75 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| កំពង់ធំ | : FM 103.5 Mhz | ម៉ោង ៨:០០- ៩:០០ រាល់ថ្ងៃ |
| កំពង់ចាម | : FM 100.5 Mhz | ម៉ោង ៨:០០- ៩:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : FM 103.5 Mhz | ម៉ោង ៦:០០- ៧:០០ រាល់ថ្ងៃ |
| កំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

### ✣ ផ្សាយតាមរលកធាតុអាកាសខ្លី (SW)

ជាភាសាខ្មែររយៈពេល ២៧ នាទីរាល់ថ្ងៃពីម៉ោង ៥:០០-៥:២៧នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

### ✣ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង

លោកអ្នកអាចស្ដាប់កម្មវិធីវិទ្យុវីរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Veritas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។

Radio Veritas Asia

Khmer Live audio

ឬ តាមរយៈវេបសាយ៖ http://rvakhmer.com